


សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស

លីកាដូ

LICADHO

Cambodian League for the
Promotion and Defense of
Human Rights


# ដីដែលមិនអាចដាំដំណាំបាន៖

## ការពិនិត្យទៅលើសម្បទានដីសង្គមកិច្ច


របាយការណ៍សង្ខេបចេញផ្សាយ
ខែមិថុនា ឆ្នាំ២០១៥

# ដីដែលមិនអាចដាំដំណាំបាន៖

## ការពិនិត្យទៅលើសម្បទានដីសង្គមកិច្ច

របាយការណ៍សង្ខេបចេញផ្សាយ ខែមិថុនា ឆ្នាំ២០១៥


**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ មក អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ការគោរពសិទ្ធិទាំងនោះ ពីរាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលរាជរដ្ឋាភិបាលតាមរយៈកម្មវិធីសិទ្ធិមនុស្សនានា ពីការិយាល័យកណ្ដាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង ១៣ ខេត្ត-រាជធានីផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

**ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ:**

បុគ្គលិកលីកាដូ ធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយអាជ្ញាធរ ការរំលោភបំពានលើស្ត្រី និងកុមារ។ ជនរងគ្រោះ ត្រូវបានផ្ដល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

**ជំនួយផ្នែកវេជ្ជសាស្ត្រ និងសេវាកម្មសង្គមកិច្ច:**

ក្រុមគ្រូពេទ្យផ្ដល់សេវាវេជ្ជសាស្ត្រដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារចំនួន១៤ កន្លែង ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្ដល់ជំនួយជាសម្ភារៈ និងម្ហូបអាហារសម្រាប់រយៈពេលខ្លី។

**ការឃ្លាំមើលពន្ធនាគារ:**

អ្នកស្រាវជ្រាវពន្ធនាគារ ធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាជនជាប់ឃុំទទួលបាននូវតំណាងផ្នែកច្បាប់។

**ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:**

ជនរងគ្រោះ ត្រូវបានផ្ដល់ជូននូវការប្រឹក្សាផ្នែកច្បាប់ និងផ្ដល់ជូនមេធាវីសិទ្ធិមនុស្សសម្រាប់ជាតំណាងផ្លូវច្បាប់លើករណីសំខាន់ៗមួយចំនួន។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

**គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងបណ្ដាញនានា:**

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ ដែលរងគ្រោះ ដោយផ្ដល់នូវកិច្ចការពារ សេវាកម្មផ្នែកច្បាប់ ព្រមទាំងជួយពង្រឹងនូវសមត្ថភាពរបស់ពួកគេ ក្នុងការធ្វើយុទ្ធនាការ និងការតស៊ូមតិអំពីសិទ្ធិមនុស្ស។

**ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:**

បុគ្គលិកតស៊ូមតិធ្វើការអប់រំដល់ក្រុមគោលដៅជាក់លាក់មួយចំនួន បណ្ដាញគាំទ្រកិច្ចការពារសិទ្ធិមនុស្សនៅថ្នាក់មូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីជួយកែលំអសង្គមនិងច្បាប់ ជាមួយស្ត្រី យុវវ័យ និងកុមារ។

**គាំទ្រការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:**

ករណីរំលោភសិទ្ធិមនុស្ស ដែលស៊ើបអង្កេតដោយអង្គការលីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារ: (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែល: contact@licadho-cambodia.org
គេហទំព័រ: www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្តីផ្តើម ទំព័រ១

តើគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) បានទទួលជោគជ័យយ៉ាងដូចម្តេចក្នុងការកាត់បន្ថយភាពក្រីក្រ ទំព័រ៥

ការមិនមានលទ្ធភាពក្នុងការប្រើប្រាស់ដីកសិកម្ម និងកង្វះសន្តិសុខស្បៀង ៨

សុវត្ថិភាពភាពនៃជាម្ចាស់កម្មសិទ្ធិមិនទាន់ត្រូវបានធានា ១២

មូលហេតុដែលមិនជោគជ័យនៃគម្រោង LASED ទំព័រ១៦

កង្វះឆន្ទៈនយោបាយ ១៦

ការមិនអាចសម្រេចទៅបានតាមគោលដៅនៅក្នុងការផ្តល់ការគាំទ្រលើហេដ្ឋា-រចនាសម្ព័ន្ធ និងការចិញ្ចឹមជីវិតពលរដ្ឋ ១៨

សេចក្តីសន្និដ្ឋាន ទំព័រ២០




ផ្ទះដែលមិនទាន់សាងសង់រួចជាច្រើនខ្នងនៅតំបន់ដីសម្បទានសង្គមកិច្ចក្នុងភូមិថ្មី ខេត្តក្រចេះ កាលពីខែកុម្ភៈ ឆ្នាំ២០១៥




ផ្ទាំងផ្សព្វផ្សាយស្តីពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច តាមបណ្តោយផ្លូវជាតិលេខ ៧ ក្នុងខេត្តក្រចេះ បង្ហាញពីអំពីផែនទីនៃទីតាំងដីសម្បទានសង្គមកិច្ចថ្មី កាលពីខែកុម្ភៈ ឆ្នាំ២០១៥

# សេចក្តីផ្តើម

កាលពីខែមីនា ឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយ ដែលមានសក្តានុពលល្អ ដោយមានគោលបំណងបែកចែកដីជូនប្រជាពលរដ្ឋកម្ពុជាដែលក្រីក្រនិងគ្មានដីតាមរយៈសម្បទានដីសង្គមកិច្ច។[1] ទោះជាយ៉ាងណាក៏ដោយ កម្មវិធីសម្បទានដីសង្គមកិច្ចខ្លះ នៃកម្មវិធីសម្បទានដីសង្គមកិច្ចជំហានទី១ ត្រូវបានអនុវត្តដោយមិនធ្វើការពិចារណាទាល់តែសោះ ទៅលើក្រមខណ្ឌគតិយុត្តិ និងមិនបានជោគជ័យ។[2] គម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) ត្រូវបានបង្កើតឡើង ដើម្បីបង្ហាញថា កម្មវិធីដីសម្បទានសង្គមកិច្ចអាចចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅជនបទ តាមរយៈការផ្ទេរដីទៅឲ្យប្រជាពលរដ្ឋកម្ពុជា ដែលគ្មានដីសម្រាប់កសាងលំនៅស្ថាននិងប្រកបរបរកសិកម្ម។

ម្ចាស់ជំនួយរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) នេះ រួមមានធនាគារពិភពលោក (សន្យាផ្តល់ថវិកាចំនួន ១១,៥ លានដុល្លារសហរដ្ឋអាមេរិក) និងរដ្ឋាភិបាលរបស់ប្រទេសអាល្លឺម៉ង់ (ចំនួន ១,២ លានដុល្លារសហរដ្ឋអាមេរិក សម្រាប់ជំនួយបច្ចេកទេស ដែលគ្រប់គ្រងចាត់ចែងដោយភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GTZ/GIZ)។[3] គម្រោងនេះបានចាប់ផ្តើមកាលពីឆ្នាំ ២០០៨[4] ហើយដំបូង គ្រោងអនុវត្តក្នុងរយៈពេលប្រហែល ៥ ឆ្នាំរហូត ដល់ខែមិថុនា ឆ្នាំ២០១៣ ប៉ុន្តែក្រោយមក ត្រូវបានពន្យារពេលរហូតដល់ខែមីនា ឆ្នាំ២០១៥។[5] គោលបំណងនៃគម្រោងនេះ "គឺធ្វើឲ្យ ប្រសើរឡើងនូវដំណើរការក្នុងការកំណត់ និងការប្រើប្រាស់ដីរដ្ឋដែលបានបែងចែងទៅឲ្យប្រជាពលរដ្ឋក្រីក្រនិងអតីតអ្នកគ្មានដី ឬអ្នកខ្វះខាតដីដែលបានបំពេញទៅតាមលក្ខខណ្ឌរបស់គម្រោង ហើយ

---

[1] សូមមើលអនុក្រឹតលេខ១៩ ស្តីពីសម្បទានដីសង្គមកិច្ច ដែលមាននៅលើគេហទំព័រ http://www.cambodiainvestment.gov.kh/sub-decree-19-on-social-land-concesions_030319.html

[2] សូមមើលរបាយការណ៍របស់អង្គការលីកាដូ ដែលមានចំណងជើងថា "ការរំលោភយកដីធ្លី និងភាពក្រីក្រនៅកម្ពុជាៈ ការអភិវឌ្ឍក្លែងក្លាយ" ខែឧសភា ឆ្នាំ២០០៩ ទំព័រ ១១ ដែលមាននៅលើគេហទំព័រ http://www.licadho-cambodia.org/reports/files/134LICADHOREportMythofDevelopment2009Eng.pdf

[3] របាយការណ៍វាយតម្លៃគម្រោង ឆ្នាំ២០០៨ ទំព័រ៦ ដែលមាននៅលើគេហទំព័រ http://documents.worldbank.org/curated/en/2008/04/9415731/cambodia-land-allocation-social-economic-development-project។ សូមមើលឯកសារស្តីពីគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) របស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់(GIZ) - ឯកសារ ស្តីពីគម្រោង LASED (ឯកសាររបស់ GIZ): http://giz-cambodia.com/wordpress/wp-content/uploads/FactSheet-LASED-140529.pdf ទាញយកកាលពីថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៥។ សូមកត់សម្គាល់: Deutsche Gesellschaft für Technische Zusammenarbeit (GTZ) បានរួមបញ្ចូលគ្នាជាមួយអង្គការពីរផ្សេងទៀត កាលពីឆ្នាំ២០១១ ដើម្បីបង្កើតជា Deutsche Gesellschaft für Internationale Zusammenarbeit (GIZ)។

[4] អង្គការ GIZ អះអាងថា ការសាកល្បងគម្រោងសម្បទានដីសង្គមកិច្ចនៅកម្ពុជាបានចាប់ផ្តើមទាំងពីឆ្នាំ២០០៥ មកម្ល៉េះ។ សូមមើល "ការបែងចែកដីថ្នាក់ឃុំដើម្បីការបន្ថយភាពក្រីក្រនៅកម្ពុជាៈ សមិទ្ធផល និងការរៀនសូត្រពីគម្រោងៈ គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED)" (ឯកសាររបស់ GIZ) ទំព័រ ៦ ដែលមាននៅលើគេហទំព័រ http://www.landandpoverty.com/agenda/pdfs/paper/muller_full_paper.pdf

[5] របាយការណ៍ទាក់ទងនឹងការរៀបចំ និងវឌ្ឍនភាពនៃគម្រោង LASED ដែលមានជាសាធារណៈ គឺឯកសារវាយតម្លៃគម្រោង និងរបាយការណ៍ស្តីពីស្ថានភាពគម្រោង LASED របស់ធនាគារពិភពលោក។ ឯកសារទាក់ទងនឹងការរៀបចំ និងវឌ្ឍនភាពនៃគម្រោង LASED របស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់មិនត្រូវបានផ្សព្វផ្សាយនោះទេ។ ដូច្នេះ ព័ត៌មានដែលមានខាងក្រោមទាក់ទងនឹងការរៀបចំគម្រោងភាគច្រើនបានមកពីឯកសាររបស់ធនាគារពិភពលោក។

ដែលត្រូវបានជ្រើសរើសតាមរយៈដំណើរការមួយ ដែលប្រកបដោយតម្លាភាព និងចំគោលដៅបានល្អ។ ‶គោលបំណងបែបបរិមាណរបស់គម្រោងគឺផ្តល់ដីចំនួន ១0.000ហិកតា ទៅដល់ប្រជាពលរដ្ឋក្រីក្រចំនួន ៣.000 គ្រួសារនៅក្នុងខេត្តក្រចេះ កំពង់ចាម និងកំពង់ធំ ដោយមានទាំងការអភិវឌ្ឍសហគមន៍ រួមជាមួយនឹងការផ្តល់សេវាគាំទ្រផ្នែកកសិកម្ម និងការចិញ្ចឹមជីវិត។[៦]

ការរៀបរាប់របស់ធនាគារពិភពលោកនិងភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GTZ/GIZ) ទាក់ទងនឹងគម្រោងនេះ គឺមានភាពវិជ្ជមានយ៉ាងខ្លាំង។ នៅក្នុងរបាយការណ៍ចុងក្រោយរបស់ធនាគារពិភពលោកស្តីពីស្ថានភាពនៃគម្រោងនេះដែលបានផ្សព្វផ្សាយកាលពីខែធ្នូ ឆ្នាំ២០១៤ ក្នុងរយៈពេលតែប៉ុន្មានខែ មុនពេលចុងបញ្ចប់នៃគម្រោង ធនាគារពិភពលោកបានប្រកាសអំពីលទ្ធភាពក្នុងការផ្តល់កម្ចីថ្មីចំនួន ២៥ លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ជំហានទី២ នៃគម្រោងនេះ (LASED II) ដែលនឹងផ្តល់ការគាំទ្រដល់ទីតាំងដីសម្បទានសង្គមកិច្ចដែលមានស្រាប់ចំនួន ១៤ និង ទីតាំងដីសម្បទានសង្គមកិច្ចថ្មីចំនួនមួយ ដែលក្នុងនោះរួមទាំ ង ទីតាំងដីសម្បទាសង្គមកិច្ចទាំង ៨ ដែលបានទទួលការគាំទ្រពីគម្រោងជំហានទី១។ ប្រសិនបើកម្ចីថ្មីនេះត្រូវបានអនុម័ត វានឹងក្លាយជាកម្ចីរបស់ធនាគារ ពិភពលោកដំបូងបំផុតចាប់តាំងពីធនា គារនេះ បានសម្រេចព្យួរការផ្តល់ហិរញ្ញប្បទានមកឲ្យកម្ពុជាកាលពីឆ្នាំ២០១១ បន្ទាប់ពីមានការស៊ើបអង្កេតអស់រយៈពេល ១៨ ខែ ដោ យសវនការផ្ទៃក្នុងរបស់ធនាគារនេះ ទៅលើគម្រោងផ្តល់ប័ណ្ណក ម្មសិទ្ធិដីធ្លីដែលឧបត្ថម្ភដោយធនាគារនេះ ដែលឃើញថាមានការរើសអើងចំពោះប្រជាពលរដ្ឋរស់នៅតំបន់បឹងកក់ ក្នុងទីក្រុង




ធនាគារពិភពលោកបានផ្តល់ពិន្ទុល្អបំផុតទាំងទៅលើការសម្រេចទៅតាមគោលបំណងរបស់គម្រោង និងការសម្រេចបានទៅតាមសូចនាករដែលពាក់ព័ន្ធ រួមទាំងដំណើរការនៃការអនុវត្តគម្រោងទាំងមូល។[៧] ភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GTZ/GIZ) បានពណ៌នាអំពីការសម្រេចបានរបស់គម្រោងនេះ ថាជា ‶គម្រោងគំរូដ៏មានប្រសិទ្ធភាព និងអាច យកអនុវត្តតាម ដែលបានផ្តល់ផលវិជ្ជមានដ៏ធំធេងចំពោះជីវភាពរស់នៅនៅជនបទ ឥឡូវនេះមានសម្រាប់ការយកផ្សព្វផ្សាយទូទាំងប្រទេស និងធ្វើឲ្យកាន់តែប្រសើរថែមទៀត″។[៨] ក្នុងឆ្នាំ២០១៤ ភ្នំពេញ។ ជម្លោះដីធ្លីនៅតំបន់បឹងកក់ជាជម្លោះដីធ្លីក្នុងតំបន់ទីក្រុងដ៏ធំបំផុតមួយ និងត្រូវបានគេដឹងឮច្រើនបំផុត ហើយរបាយការណ៍របស់សវនករបានរកឃើញថា គម្រោងនេះមិនបានជោគជ័យក្នុងការការពារសិទ្ធិលំនៅស្ថានរបស់ប្រជាពលរដ្ឋរាប់ពាន់នាក់ ដែលត្រូវបណ្តេញចេញដោយបង្ខំចេញពីតំបន់នោះ បន្ទាប់ពីមិនត្រូវបានដាក់បញ្ចូលទៅក្នុងគម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនោះ។ នាពេលនោះ ធនាគារពិភពលោកបានសន្យាថា ហិរញ្ញប្បទានថ្មីរបស់ធានាគារនេះនឹងមិនផ្តល់ទៀតទេ រហូតដល់មានដំណោះស្រាយចំពោះជម្លោះដីធ្លី

[៦] ឯកសារវាយតម្លៃគម្រោងឆ្នាំ២០០៨ ទំព័រ ៧។
[៧] សូមមើលរបាយការណ៍ស្តីពីលទ្ធផលនៃស្ថានភាពអនុវត្តគម្រោងរបស់ធនាគារពិភពលោក កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៤ (របាយការណ៍របស់ធនាគារពិភពលោក) ដែលមាននៅលើគេហទំព័រ http://documents.worldbank.org/curated/en/2014/12/23071237/cambodia-land-allocation-social-economic-development-p084787-implementation-status-results-report-sequence-09
[៨]ឯកសារអំពីគម្រោងរបស់ភ្នាក់ងារកិច្ចសហប្រតិបត្តិអាល្លឺម៉ង់ដែលមាននៅលើគេហទំព័រhttp://giz-cambodia.com/wordpress/wp-content/uploads/FactSheet-LASED-140529.pdf



តំបន់លំនៅស្ថានក្នុងទីតាំងដីសម្បទានសង្គមកិច្ចក្នុងឃុំដារ ខេត្តក្រចេះ កាលពីខែកុម្ភៈ ឆ្នាំ២០១៥

នៅតំបន់បឹងកក់ ដែលជាលក្ខខណ្ឌមួយដែលមិនទាន់បានបំពេញឲ្យបានពេញលេញនៅឡើយទេ។

## ដីដែលបានបែងចែកឲ្យដោយអាជ្ញាធរកម្ពុជា (យ៉ាងហោចណាស់ផ្នែកខ្លះនៃដីទាំងនោះ) ហាក់ដូចជាមិនសមស្របសម្រាប់ការធ្វើកសិកម្មនោះទេ។

នៅចន្លោះខែតុលា ឆ្នាំ២០១៤ និងខែមីនា ឆ្នាំ២០១៥ ក្រុមការងាររបស់អង្គការ លីកាដូ បានធ្វើទស្សនកិច្ចទៅកាន់ទីតាំងដីសម្បទានសង្គមកិច្ចទាំង ៨ ដែលគាំទ្រដោយគម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) ដែលស្ថិតនៅក្នុងឃុំ ៧ ក្នុងខេត្តកំពង់ធំ ក្រចេះ និងត្បូងឃ្មុំ (អតីតស្រុកមួយនៃខេត្តកំពង់ចាម)។ ក្រុមការងាររបស់អង្គការ លីកាដូ បានធ្វើទ ស្សនកិច្ចទៅកាន់ទីតាំងដីសម្បទានសង្គមកិច្ចទាំងអស់នោះ ដោយមិនមានការជម្រាបជូនដំណឹងទុកជាមុនដល់អាជ្ញាធរ ហើ យក្រុមការងារបានធ្វើការសង្កេត និងធ្វើការសម្ភាសក្រៅផ្លូវការជាមួយអ្នកភូមិ (អ្នកដែលអង្គការ លីកាដូ បានសម្ភាស ត្រូ វ បានជ្រើសរើសដោយមិនមានការគ្រោងទុកជាមុន) នៅទីតាំងទាំងនោះ ដោយរួមទាំងអ្នកដឹកនាំសហគមន៍ និងគ្រូបង្រៀនទៀតផង ។ អ្នកដែលអង្គការ លីកាដូ បានសម្ភាស ត្រូវបានសាកសួរអំពីស្ថានភាពជីវិត និងយុទ្ធសាស្ត្រសម្រាប់ការចិញ្ចឹមជីវិត ដែលអ្នកទាំងអស់នោះបានជួបប្រទះនៅទីនោះ។ អង្គការ លីកាដូ ក៏បានធ្វើការសិក្សាទៅលើឯកសាររបស់គម្រោងនេះ ដែលមានផ្សព្វផ្សាយជាសាធារណៈ នៅលើគេហទំព័ររបស់ធនាគារពិភពលោក[៩] និងឯកសារដែលមានផ្សព្វផ្សាយជាសាធារណៈដទៃទៀត។

បើទោះជាគោលបំណងរបស់គម្រោងទាក់ទងនឹងការផ្តល់ដីលំនៅ ស្ថាន និងដីកសិកម្មទៅដល់ប្រជាពលរដ្ឋចំនួន ៣.០០០ គ្រួសារ ត្រូវបានសម្រេចរួចហើយក៏ដោយ ក៏អង្គការ លីកាដូ បាន់ប្រមាណថា ប្រហែលមានតែប្រជាពលរដ្ឋតិចជាង ៥០ ភាគរយនៃចំនួនគ្រួសារដែលបានទទួលដីលំនៅស្ថានបានរស់នៅ និងបន្តរស់នៅទីនោះ នាពេលទស្សនកិច្ចរបស់ក្រុមការងាររបស់អង្គការ លីកាដូ ទៅដល់ទីកន្លែងទាំងនោះ។ នាពេលទស្សនកិច្ចរបស់ក្រុមការងារអង្គការ លីកាដូ ក្នុងចំណោមទីតាំងទាំង ៨កន្លែង ទីតាំងដីសម្បទានសង្គមកិច្ចចំនួន ៤ កន្លែង មិនទាន់ដំណើរការនៅឡើយទេ ហើយនឹងត្រូវការការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសជាច្រើន ដើម្បីអាច

[៩] សូមមើល http://documents.worldbank.org/curated/en/docsearch/projects/P084787%5EP084787

ទទួលបាននិរន្តរភាពបន្តិចបន្តួច។

ប្រជាពលរដ្ឋជាច្រើនដែលរស់នៅលើទីតាំងទាំង ៧ កន្លែង ក្នុងចំណោមទីតាំងទាំង ៨ កន្លែង បានជម្រាបប្រាប់អំពីលទ្ធភាពដ៏តិចតួចក្នុងការបង្កបង្កើនផលលើដីកសិកម្ម ដែលអ្នកទាំងអស់នោះទទួល បាន ហើយដូច្នេះស្ថានភាពសន្តិសុខស្បៀងរបស់អ្នកទាំងអស់នោះ មិនបានប្រសើរជាងមុនប៉ុន្មានទេ។ ដីដែលបានបែងចែកឲ្យដោយអាជ្ញាធរកម្ពុជា (យ៉ាងហោចណាស់ផ្នែកខ្លះនៃដីទាំងនោះ) ហាក់ដូចជាមិនសមស្របសម្រាប់ការធ្វើកសិកម្មនោះទេ។ អ្នកភូមិជាច្រើនបានរាយការណ៍ថា ពួកគាត់មិនអាចបង្កបង្កើនផលឲ្យបានត្រឹមត្រូវនៅលើដីកសិកម្មដែលបែងចែកឲ្យទេ ដោយសារតែដីមិនសូវមានជីជាតិ និង/ឬអ្នកទាំងនោះមិនមានឧបករណ៍ចាំបាច់មួយចំនួន និងកម្លាំងមនុស្សដើម្បីរានសម្អាតដី និងរៀបចំដីនោះសម្រាប់ការបង្កបង្កើនផល។ ជាលទ្ធផល ការកាត់បន្ថយភាពក្រីក្រចំពោះអ្នកទទួលដីសម្បទានសង្គមកិច្ចភាគច្រើន មិនទាន់សម្រេចបាននោះទេនៅចុងបញ្ចប់នៃគម្រោងនេះ។

ជាងនេះទៅទៀត សុវត្ថិភាពនៃកម្មសិទ្ធិដីមិនទាន់ត្រូវបានធានានៅឡើយដែរ ហើយអ្នកភូមិបានប្រាប់អង្គការ លីកាដូ ថា មិនទាន់មានអ្នកភូមិណាម្នាក់ទទួលបានប័ណ្ណកម្មសិទ្ធិដីនៅឡើយទេ។ អ្នកភូមិដែលបានកាន់កាប់ដីអស់រយៈពេលជាង ៥ ឆ្នាំមកហើយ នៅកំពុងរង់ចាំប័ណ្ណកម្មសិទ្ធិ ហើយអ្នកភូមិច្រើនផ្សេងទៀត ប្រហែលជាបាត់បង់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ ដោយសារតែការអនុវត្តមិនបានល្អរបស់គម្រោង បង្ខំឲ្យពួកគាត់រំលោភលក្ខខណ្ឌផ្លូវច្បាប់ ដែលពួកគាត់ត្រូវបំពេញដើម្បីអាចស្នើសុំប័ណ្ណកម្មសិទ្ធិបាន។

បន្ទាប់ពីការអនុវត្តគម្រោងអស់រយៈពេល ៦ ឆ្នាំកន្លះ កន្លងមកការទទួលបាននូវសមិទ្ធផលដ៏មានកម្រិតនេះ បណ្តាលមកពីការមិនសូវមានឆន្ទៈនយោបាយរបស់មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា ដែលពាក់ព័ន្ធក្នុងការផ្តល់ដីឲ្យបានគ្រប់គ្រាន់ សម្រាប់សម្បទានដីសង្គម-កិច្ច និងឲ្យបានទាន់ពេលវេលា។ ការមិនសូវមានឆន្ទៈនយោ-បាយបានបណ្តាលឲ្យមានការពន្យារពេលយូរចំពោះដំណើរការនៃការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ នៅទីតាំងដីសម្បទានសង្គមកិច្ចទាំងនោះ។ បញ្ហានេះកាន់តែមានសភាពធ្ងន់ធ្ងរបន្ថែមទៀត ដោយសារការខ្វះខាតក្នុងការផ្តល់ការគាំទ្រផ្នែកហេដ្ឋារចនាសម្ព័ន្ធ និងការគាំទ្រផ្នែកជីវភាពសំខាន់ៗ ដល់អ្នកទទួលបានដីសម្បទានសង្គមកិច្ចជាច្រើនគ្រួសារ។ ផ្ទុយទៅវិញ ស្របពេលជាមួយគ្នានោះដែរ រាជរដ្ឋាភិបាលកម្ពុជាមិនមានភាពរារែកសោះ ក្នុងការផ្តល់ដីរាប់រយពាន់ហិកតាទៅឲ្យក្រុមហ៊ុនឯកជនតាមរយៈសម្បទានដីសេដ្ឋកិច្ច (ELCs)។

# តើគម្រោងបែងចែកដី ដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) មិនទទួលបានជោគជ័យយ៉ាងដូចម្ដេច ក្នុងការកាត់បន្ថយភាពក្រីក្រ?

ក្របខ័ណ្ឌនៃគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) បានរំពឹងបង្កើតនូវភាពជាគំរូមួយ សម្រាប់ការបែកចែកដីថ្នាក់ឃុំដល់ប្រជាពលរដ្ឋកម្ពុជាដែលក្រីក្រ និងខ្វះខាតដីនៅតាមជនបទ។ គម្រោងនេះបានព្យាយាមទាក់ទាញផ្នែកនយោបាយចំពោះសម្បទានដីសង្គមកិច្ច ដោយបង្ហាញនូវប្រសិទ្ធភាព និងការសម្រេចបាននូវ ″សមិទ្ធផលដ៏វិជ្ជមានទាក់ទងនឹងភាពពេញចិត្តរបស់អ្នកទទួលបានដី និងកម្រិតនៃការបោះបង់ដីទាប។″[១០]

យោងតាមរបាយការណ៍វាយតម្លៃគម្រោង គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) មានបំណងផ្ដល់ដីចំនួន១០.០០០ ហិកតា ដល់ប្រជាពលរដ្ឋចំនួន ៣.០០០ គ្រួសារត្រឹមខែកញ្ញា ឆ្នាំ២០១១។[១១] ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តគម្រោងជាក់ស្ដែងមានការពន្យារពេលយូរ ដែលធ្វើឲ្យប៉ះពាល់ដល់ឱកាសក្នុងការសម្រេចបាននូវនិរន្តរភាព ឬការបង្កើនសន្តិសុខស្បៀងឲ្យបានគ្រប់គ្រាន់។ ត្រឹមខែតុលា ឆ្នាំ២០១១ បីឆ្នាំបន្ទាប់ការចាប់ផ្ដើមអនុវត្តគម្រោង ប្រជាពលរដ្ឋត្រឹមតែ ១.៦១៤ គ្រួសារប៉ុណ្ណោះទទួលបានដី (៥៤ ភាគរយនៃគោលដៅដែលចង់សម្រេចបាន) ហើយដីត្រឹមតែ ៦.៨៥០,៦ហិកតាប៉ុណ្ណោះ (៦៨,៥ ភាគរយនៃគោលដៅដែលចង់សម្រេចបាន) ត្រូវបានចុះជាដីសម្បទានសង្គមកិច្ច។[១២]

គម្រោងនេះក៏មានគោលបំណងចំណាយថវិកាចំនួន ៤,៨ លានដុល្លារសហរដ្ឋអាមេរិកត្រឹមចុងឆ្នាំ២០១១ ទៅលើការតាំងទីលំនៅ និងការគាំទ្រផ្នែកជីវភាពដល់អ្នកទទួលបានដីនិងទៅលើយ៉ាងតិចណាស់ ៨០ ភាគរយនៃសេវាអភិវឌ្ឍន៍សហគមន៍។ ក៏ប៉ុន្តែ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាផ្សេងៗមានត្រឹមតែ ៤៥ ភាគរយប៉ុណ្ណោះ (ជំនួសឲ្យ ៨០ ភាគរយដែលបានគ្រោងទុក) ដែលត្រូវបានផ្ដល់ជូនពលរដ្ឋត្រឹមខែសីហា ឆ្នាំ២០១២។[១៣]




តាមរយៈរូបភាពពីផ្កាយរណបដែលបង្ហាញពីតំបន់លំនៅស្ថានក្នុងទីតាំងដីសម្បទានសង្គមកិច្ចនៅឃុំដារ អង្គការ លីកាដូ បានរកឃើញថាមានសំណង់ចំនួន ១០៨ខ្នង នៅក្នុងតំបន់លំនៅស្ថាននោះ។ ប្រជាពលរដ្ឋជិត ៣០០គ្រួសារ បានទទួលដីលំនៅស្ថាននៅក្នុងតំបន់នោះ។
រូបភាពពីផ្កាយរណប កាលពីខែធ្នូ ឆ្នាំ២០១៣

[១០] សូមមើលឯកសារស្ដីពីការវាយតម្លៃគម្រោង ឆ្នាំ២០០៨ ទំព័រ១៨។
[១១] សូមមើលឯកសារស្ដីពីការវាយតម្លៃគម្រោង ឆ្នាំ២០០៨ ទំព័រ៥២។
[១២] របាយការណ៍ស្ដីពីស្ថានភាពគម្រោង LASED របស់ធនាគារពិភពលោកចេញផ្សាយ កាលពីខែមករា ឆ្នាំ២០១២ ទំព័រ៤ ដែលមាននៅលើគេហទំព័រ http://documents.worldbank.org/curated/en/2012/01/15589815/cambodia-land-allocation-social-economic-development-p084787-implementation-status-results-report-sequence-04
[១៣] សូមមើលឯកសារស្ដីពីការវាយតម្លៃគម្រោង ឆ្នាំ២០០៨ ទំព័រ៥២ និង៦៤ និងរបាយការណ៍ស្ដីពីស្ថានភាពគម្រោង LASED របស់ធនាគារពិភពលោក ចេញផ្សាយកាលពីខែធ្នូ ឆ្នាំ២០១២ ទំព័រ៦ ដែលមាននៅលើគេហទំព័រ http://documents.worldbank.org/curated/en/2012/12/17078699/cambodia-land-allocation-social-economic-development- p084787-implementation-status-results-reportsequence-05



ដីស្រែដែលមិនអាចដាំដុះបាននៅទីតាំងដីសម្បទានសង្គមកិច្ច ក្នុងឃុំដារ ខេត្តក្រចេះ កាលពីខែកុម្ភៈ ឆ្នាំ២០១៥

## ករណីសិក្សា៖ ឃុំដារ

ផ្ទាំងផ្សព្វផ្សាយដ៏ធំមួយតាមបណ្តោយផ្លូវជាតិលេខ ៧ ដែលស្ថិតក្នុងស្រុកចិត្របុរី ខេត្តក្រចេះ បានរៀបរាប់អំពីកសិករខិតខំប្រឹងប្រែងក្នុងការដាំដំណាំស្រូវ និងក្មេងៗកំពុងលេងនៅទីធ្លាសាលារៀន។ ផ្ទាំងផ្សព្វផ្សាយនោះ បានបង្ហាញដល់អ្នកដែលធ្វើដំណើរឆ្លងកាត់អំពីសម្បទានដីសង្គមកិច្ច (SLC)ជូនប្រជាពលរដ្ឋចំនួន ៤០២ គ្រួសារ ដែលធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជាដែលមានជំនួយពីធនាគារពិភពលោក និងភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់(GIZ)តាមគោលការណ៍របស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច (LASED)។ ផ្ទៃដីត្រូវបានចុះ បញ្ជីជាដីសម្បទានសង្គមកិច្ចក្នុងឃុំដារ នៅឆ្នាំ២០១០[១៤] ហើយក្រុមគ្រួសារដំបូងបានចាប់ផ្តើមតាំងទីលំនៅនៅចុងឆ្នាំ២០១២។ ក្រុមការងាររបស់អង្គការលីកាដូ ក៏បានចុះទៅដល់តំបន់ នោះ កាលពីខែកុម្ភៈ ឆ្នាំ២០១៥ (មួយខែមុនពេលដែលគម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) ត្រូវបានបញ្ចប់) ដើម្បីស្រង់យកព័ត៌មានពីអ្នកភូមិ អំពីផលប៉ះពាល់របស់គម្រោងសម្បទានដីសង្គមកិច្ចមកលើជីវិតរបស់អ្នកទាំងនោះ។

ស្ត្រីម្នាក់ឈ្មោះ ដារី ដែលមានអាយុជាង ៣០ ឆ្នាំ (មិនមែនជាឈ្មោះពិតរបស់នាងទេ) បានប្រាប់អង្គការ លីកាដូ ថា ទោះបីជាឥឡូវនេះនាងមានការសប្បាយចិត្តក្នុងការទទួលបានដីលំនៅឋានមួយសម្រាប់រស់នៅផ្ទាល់ខ្លួនក៏ដោយ ក៏ស្ថានភាពជីវភាពរស់នៅ និងសន្តិសុខស្បៀងរបស់គ្រួសារនាង ស្ទើរតែមិនមានការផ្លាស់ប្តូរទាល់តែសោះ ចាប់តាំងពីពេលដែលនាងបានផ្លាស់ទីលំនៅមករស់នៅក្នុង ភូមិថ្មីកាលពីចុងឆ្នាំ២០១២។ រៀងរាល់ថ្ងៃ ដារី និងស្វាមីនៅតែតស៊ូពេញមួយថ្ងៃ ដើម្បីរកម្ហូបអាហារឲ្យបានគ្រប់គ្រាន់ដើម្បីចិញ្ចឹមកូនចំនួន ៥នាក់។ ដោយយោងទៅតាមសម្តីរបស់ ដារី ផ្ទៃដីកសិកម្មដែលត្រូវបានបែងចែកទៅដល់ក្រុមគ្រួសាររបស់នាងគឺពោរពេញទៅដោយថ្ម ហើយជាដីមិនមានជីជាតិ។ ផ្ទៃដីកសិកម្មភាគច្រើនត្រូវបានគ្របដណ្តប់ទៅដោយព្រៃ ហើយក្រុមគ្រួសាររបស់នាងខ្វះខាតសម្ភារៈកាប់ឆ្ការព្រៃដើម្បីរៀបចំដីធ្វើកសិកម្ម។ ជាដំបូង ដារី និងស្វាមីរបស់នាងបានព្យាយាមដាំដើមដំឡូងមី ប៉ុន្តែទិន្នផលដែលទទួលបានមានចំនួនតិចតួចប៉ុណ្ណោះ។

ដោយសារតែក្រុមគ្រួសារមិនអាចបន្តរស់នៅ ដោយពឹងលើដីកសិកម្មទាំងអស់នោះបាន អ្នកទាំងអស់នោះបានឈប់ធ្វើការដាំដុះទាំងស្រុង។ គ្រួសាររបស់នាងនៅមានចំការបន្លែតូចមួយនៅផ្ទះ ដែលដារីបានបង្កើតឡើងក្រោយពេលដែលនាងបានទទួលការបណ្តុះបណ្តាល ដែលជាផ្នែកមួយនៃគម្រោងបែងចែកដីដើម្បី សង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច (LASED)។ ក៏ប៉ុន្តែ ប្រភពចំណូលដ៏សំខាន់របស់គ្រួសារគឺទទួលបានមកពីពលកម្មប្រចាំថ្ងៃ ឬតាមរដូវ។ ដារី បានប្រាប់អង្គការលីកាដូ ថា នាងទើបតែបានត្រលប់មកពីធ្វើការងារនៅចំការស្វាយចន្ទីក្នុងខេត្តរតនគិរីពីរបីថ្ងៃមុនពេលសម្ភាសប៉ុណ្ណោះ។ ស្វាមីរបស់នាងក៏កំពុងតែធ្វើការជាកម្មករធម្មតានៅដីស្រែចំការក្បែរនោះផងដែរ។

តាមផ្លូវចូលទៅភូមិរំលងពីពីរទៅបីផ្ទះ សុភ័ក្រ (មិនមែនជាឈ្មោះពិតរបស់នាង) កំពុងអង្គុយ និងមើលថែទាំកូនរបស់នាង។ សុភ័ក្រ និងស្វាមីរបស់នាងបានផ្លាស់ទីលំនៅមករស់នៅក្នុងតំបន់ដីសម្បទានសង្គមកិច្ច កាលពីឆ្នាំ២០១២ បន្ទាប់ពីគាត់បានទទួលដីឡូតិ៍តូចមួយសម្រាប់ធ្វើជាដីលំនៅស្ថាន និងដីចំនួនមួយហិកតាសម្រាប់ធ្វើជាដីស្រែចំការ។ ប៉ុន្តែនៅពេលដែលក្រុមគ្រួសាររបស់នាងបានទៅដល់ទីកន្លែងនោះ ដីសម្រាប់ធ្វើស្រែចំការនោះត្រូវបានកាន់កាប់រួចទៅហើយ ដោយ 'អ្នកមកពីខាងក្រៅដីសម្បទានសង្គមកិច្ច' ហើយអ្នកមកពីខាងក្រៅទាំងនោះកំពុងធ្វើការដាំដុះទៅវិញ។ ក្រុមគ្រួសាររបស់នាងបានជូនដំណឹងម្តងហើយម្តងទៀតទៅដល់អាជ្ញាធរភូមិអំពីទំនាស់ដីធ្លីនេះ ប៉ុន្តែមិនមានដំណោះស្រាយទាល់តែសោះ។ សុភ័ក្រ ស្វាមីរបស់នាង និងកូនចំនួន ៣នាក់ រស់នៅដោយពឹងផ្អែកលើប្រាក់ខែបន្តិចបន្តួចរបស់ស្វាមីជាទាហាន។ សុភ័ក្រនិយាយថា ជីវិតរបស់គ្រួសារនាងមិនមានអ្វីប្រែប្រួលច្រើនជាងពីពេលមុននោះទេ លើកលែងតែបច្ចុប្បន្ននេះនាងមានផ្ទះតូចមួយផ្ទាល់ខ្លួន និងមិនបន្តស្នាក់នៅក្នុងបន្ទាយទាហានជាមួយស្វាមីរបស់នាង

[១៤] សូមមើលអត្ថបទរបស់ GIZ ទំព័រ ២៣។

ទៀតទេ។

មានអ្នកដឹកនាំសហគមន៍ម្នាក់បានប្រាប់អង្គការ លីកាដូ ថាបទពិសោធន៍ដែល ដាវី និងសុភ័ក្រ្តបានជួបប្រទះពាក់ព័ន្ធនឹងការមិនមានលទ្ធភាពធ្វើស្រែចំការឲ្យបានល្អនៅលើផ្ទៃដីកសិកម្មដែលត្រូវបានបែងចែកទៅឲ្យអ្នកទាំងនោះ គឺមិនមែនជាករណីពិសេសនោះទេ តែនេះជាបញ្ហាទូទៅទៅហើយរបស់តំបន់ដែលត្រូវបានផ្តល់ជាដីសម្បទានសង្គមកិច្ច។ បើយោងទៅតាមអ្នកដឹកនាំសហគមន៍នោះ គឺមានពលរដ្ឋចំនួនតែ ៩៧គ្រួសារប៉ុណ្ណោះទេ ដែលបានតាំងទីលំនៅឋាននៅក្នុងភូមិ បើគិតត្រឹមតែដល់ខែកុម្ភៈ ឆ្នាំ២០១៥។ ក្នុងចំណោមពលរដ្ឋទាំងនោះ ពលរដ្ឋចំនួនប្រហែលជា ២០គ្រួសារប៉ុណ្ណោះ ដែលអាចរស់នៅដោយធ្វើការបង្កបង្កើនផលលើដីស្រែចំការដែលត្រូវបានបែងចែកឲ្យនោះ។ បញ្ហាចម្បងដែលអ្នកដែលទទួលបានដីធ្លីប្រឈមមុខនោះ គឺផ្នែកខ្លះនៃដីកសិកម្មគឺមិនមានជីជាតិ និងផ្នែកផ្សេងទៀតនៅជាព្រៃនៅឡើយ ហើយអ្នកភូមិជាច្រើនខ្វះខាតសម្ភារៈសម្រាប់កាប់ឆ្ការ និងរៀបចំដីធ្លី។ បញ្ហាផ្សេងទៀត គឺថាដីស្រែចម្ការដែលស្ថិតនៅចុងទីតាំងដីសម្បទានសង្គមកិច្ចជាញឹកញាប់ត្រូវបានទន្ទ្រានយកពីសំណាក់អ្នកមកពីខាងក្រៅ (អ្នកដែលមិនមែនជាអ្នកទទួលបានដីសម្បទានសង្គមកិច្ច)។ ហេតុដូចនេះហើយអសន្តិសុខស្បៀង គឺជាបញ្ហាដ៏ធំមួយនៅក្នុងសហគមន៍។

អ្នកភូមិជាច្រើនលើសលុបពឹងផ្អែកលើកំលាំងពលកម្មប្រចាំថ្ងៃ ដោយអ្នកភូមិមួយចំនួនធំធ្វើដំណើរទៅកាន់ខេត្តរតនគិរី ដើម្បីធ្វើការងារនៅក្នុងចម្ការស្វាយចន្ទី។ គ្រូបង្រៀនម្នាក់ដែលត្រូវបានសម្ភាសដោយអង្គការ លីកាដូ បានមានប្រសាសន៍ថា ការប្រកបរបរចិញ្ចឹមជីវិតដែលមិនមានភាពទៀតទាត់ទាំងនេះ ក៏អាចបណ្តាលឲ្យអត្រាក្នុងការបោះបង់ចោលសាលារៀនមានកម្រិតខ្ពស់នៅសាលាបឋមសិក្សាក្នុងភូមិមួយដែលត្រូវបានសាងសង់ឡើងដោយធនាគារពិភពលោក។ លោកគ្រូបានមានប្រសាសន៍បន្តទៀតថា ចំនួនកូនសិស្សប្រហែលជា ១០០នាក់បានចុះឈ្មោះចូលរៀននៅថ្ងៃបើកបវេស្សនកាល ប៉ុន្តែមានសិស្សចំនួនជិត ៥០ភាគរយបានឈប់រៀននៅពាក់កណ្តាលឆ្នាំ ដោយសារតែក្មេងៗមួយចំនួនត្រូវជួយការងារគ្រួសារដើម្បីជីវភាពរស់នៅ។ ក្មេងៗមួយចំនួនបានទៅកាប់ឈើក្នុងព្រៃជុំវិញនោះ ឬធ្វើការងារធម្មតានៅស្រែចម្ការក្បែរនោះ។ យូរៗម្តង មានមេខ្យល់មួយចំនួនធ្វើដំណើរចូលមកក្នុងភូមិដើម្បីមកយកក្មេងៗជាច្រើនក្រុមទៅធ្វើការងារនៅស្រែចម្ការតាមបណ្តាខេត្តផ្សេងៗទៀត។

បន្ទាប់ពីការពន្យារពេលជិត ២ ឆ្នាំ ធនាគារពិភពលោកបានរាយការណ៍[១៥] ថា ត្រឹមខែមេសា ឆ្នាំ២០១៣ ពីរខែមុនកាលបរិច្ឆេទរំពឹងទុកនៃការបញ្ចប់គម្រោងថា គោល-បំណងរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) ទាក់ទងនឹងការចុះបញ្ជីដី ១០.០០០ ហិកតា សម្រាប់សម្បទានដីសង្គមកិច្ច និងការជ្រើសរើសប្រជាពលរដ្ឋ ៣.០០០ គ្រួសារសម្រេចបានលើសការគ្រោងទុក ហើយថា ៦៩ ភាគរយនៃហេដ្ឋារចនាសម្ព័ន្ធ និងសេវាគាំទ្រនានាដែលបានគ្រោងត្រូវបានផ្តល់ជូន។ ជាងនេះទៅទៀត ដំណើរការនៃការតាំងទីលំនៅ នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចចំនួន ៧ កន្លែងក្នុងទីតាំងទាំង ៨ ត្រូវបានរាយការណ៍ថា កំពុងដំណើរការ ទៅនាពេលនោះ ដែលមានប្រជាពលរដ្ឋជាង២.៧៤៨គ្រួសារ។

នាពេលនោះ ធនាគារពិភពលោករំពឹងទុកថា ប្រជាពលរដ្ឋចំនួ ន ៤០០ គ្រួសារដែលសល់នឹងចាប់ផ្តើមចូលទៅរស់នៅទីតាំងដីសម្បទានសង្គមកិច្ចចុងក្រោយគេ នៅក្នុងឃុំចំ បក់ ខេត្តក្រចេះ ត្រឹមចុងខែឧសភា ឆ្នាំ ២០ ១ ៣ ។[១៦] គម្រោងនេះត្រូវបានពន្យារអស់រយៈពេលជិត ២ ឆ្នាំមកហើយរហូតដល់ចុងខែមីនា ឆ្នាំ២០១៥ ដើម្បីផ្តល់ពេលវេលាសម្រាប់ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាគាំទ្រផ្នែកកសិកម្ម និងការចិញ្ចឹមជីវិតដល់អ្នកទទួលបានដីក្នុងទីតាំងដីសម្បទានសង្គមកិច្ចថ្មីៗ។

បើទោះជាមានការពន្យារពេល របស់គម្រោងទី-តាំងដីសម្បទានសង្គមកិច្ចក្នុងឃុំទីពោ ខេត្តកំពង់ធំ និងទីតាំងដីសម្បទានសង្គមកិច្ចថ្មីចំនួន ៣កន្លែង ក្នុងខេត្តក្រចេះ មិនទាន់បានដំណើរនៅឡើយទេនៅពេលដែលក្រុមការងារអង្គការ លីកាដូ បានចុះធ្វើទស្សនកិច្ចក្នុងខែតុលា ឆ្នាំ២០១៤ និងខែកុម្ភៈ ឆ្នាំ២០១៥។ ក្នុងពេលទស្សនកិច្ចរបស់ក្រុមការងាររបស់អង្គការ លីកាដូ អង្គការ បានរកឃើញថា មានប្រជាពលរដ្ឋមួយចំនួនតូចដែលបានទៅរស់នៅលើទីតាំងដីសម្បទានសង្គមកិច្ចទាំងនោះ ដែលរួមមានប្រហែល ៦០ គ្រួសារក្នុងទីតាំងទីពោ២៩៧[១៧] គ្រួសារក្នុងទីតាំងដីសម្បទានសង្គមកិច្ចក្នុងឃុំដារប្រហែល ៣០ គ្រួសារក្នុងឃុំថ្មី និងត្រឹមតែ ៧ គ្រួសារប៉ុណ្ណោះក្នុងឃុំចំបក់។[១៨] ជាធនាគារពិភពលោកបានអះអាងថា ៨០ ភាគរយនៃប្រជាពលរដ្ឋទាំងអស់ ដែលបានទទួលដីធ្លីសម្រាប់សាងសង់លំនៅស្ថានបានចូលទៅរស់នៅរួចហើយ ក្នុងដីសម្ប-ទាននោះត្រឹមខែវិច្ឆិកា ឆ្នាំ២០១៤ក៏ដោយ ក៏តាមការស៊ើបអង្កេតរបស់អង្គការ លីកាដូ បានបង្ហាញនូវអត្រានៃអ្នកចូលទៅរស់នៅទីនោះទាបជាងអត្រា ដែលបានអះអាងដោយធនាគារពិភពលោក គឺបានត្រឹមតែតិចជាង ៥០ ភាគ

[១៥] សូមមើលរបាយការណ៍ស្តីពីស្ថានភាពគម្រោង LASED របស់ធនាគារពិភពលោក ចេញផ្សាយកាលពីខែឧសភា ឆ្នាំ២០១៣ ដែលមាននៅលើគេហទំព័រ http://documents.worldbank.org/curated/en/2013/05/17763887/cambodia-land-allocation-social-economic-development-p084787-implementation-status-results-report-sequence-06

[១៦] សូមមើលរបាយការណ៍ស្តីពីស្ថានភាពគម្រោង LASED របស់ធនាគារពិភពលោក ចេញផ្សាយកាលពីខែឧសភា ឆ្នាំ២០១៣ ទំព័រ ៥-៦។

[១៧] ត្រឹមខែតុលា ឆ្នាំ២០១៤។

[១៨] ត្រឹមខែកុម្ភៈ ឆ្នាំ២០១៥។

រយប៉ុណ្ណោះ។[១៩]

**ប្រជាពលរដ្ឋរស់នៅទីតាំងទាំងអស់នោះ នៅតែពឹងផ្អែកយ៉ាងខ្លាំង ទៅលើការធ្វើការងារប្រចាំថ្ងៃឲ្យស្រែចម្ការក្បែរៗនោះ ឬធ្វើចំណាកស្រុក (តាមរដូវ) ទៅធ្វើការនៅខេត្តផ្សេងដើម្បីរកចំណូល។**

ជាងនេះទៅទៀត តាមការរាយការណ៍របស់ប្រជាពលរដ្ឋក្នុងទីតាំងដីសម្បទានសង្គមកិច្ចភាគច្រើន ប្រជាពលរដ្ឋជាច្រើនគ្រួសារដែលបានចូលទៅរស់នៅទីតាំងដីសម្បទានសង្គមកិច្ចក្នុងឃុំដារ ថ្មី ចំបក់ ក្នុងខេត្តក្រចេះ មិនអាចបង្កបង្កើនផលលើដីកសិកម្មដែលពួកគាត់ទទួលបានឲ្យបានត្រឹមត្រូវនៅឡើយទេ។ ប្រជាពលរដ្ឋរស់នៅទីតាំងទាំងអស់នោះនៅតែពឹងផ្អែកយ៉ាងខ្លាំង ទៅលើការធ្វើការងារប្រចាំថ្ងៃឲ្យស្រែចម្ការក្បែរៗនោះ ឬធ្វើចំណាកស្រុក (តាមរដូវ) ទៅធ្វើការនៅខេត្តផ្សេងដើម្បីរកចំណូល។ គ្រួសារខ្លះបានទទួលថា ពួកគាត់បានពឹងផ្អែកលើការកាប់ឈើ ដើម្បីទទួលបានចំណូលគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។

## ការមិនមានលទ្ធភាពក្នុងការប្រើប្រាស់ដីកសិកម្ម និងការកង្វះសន្តិសុខស្បៀង

គោលបំណងរបស់គម្រោងបែងចែកដី ដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) គឺជម្រុញឲ្យអ្នកទទួលបានដី ប្រើប្រាស់ដីកសិកម្មដោយការជួយអ្នកទាំងនោះឲ្យ "អនុវត្តការគ្រប់គ្រងជីជាតិដី និងប្រព័ន្ធផលិតផលិតផលកសិកម្មឲ្យប្រសើរឡើង"។ នៅក្នុងរបាយការណ៍ចុងក្រោយបំផុតស្តីពីស្ថានភាពរបស់គម្រោង និងនៅលើគេហទំព័ររបស់ធនាគារពិភពលោក ធនាគារនេះបានអះអាងថា គោលដៅរបស់គម្រោងត្រូវបានសម្រេចបាន ១០០ភាគរយ។[២០] ត្រឹមខែឧសភា ឆ្នាំ២០១៤ កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GTZ/GIZ) បានអះអាងក្នុងចំណោមប្រជាពលរដ្ឋចំនួន ៣.១៤៨ គ្រួសារដែលទទួលបានដី ៧០ ភាគរយនៃអ្នកទាំងនោះ ត្រូវបានចាត់ថាជាអ្នកមានសន្តិសុខស្បៀង ហើយជាង ៨០ ភាគរយនៃគ្រួសារដែលទទួលបានដីមិនស្ថិតនៅក្នុងចំណោមប្រជាពលរដ្ឋ ដែលគេចាត់ថាក្រីក្រទៀតនោះទេ (IDPoor ១ និង២)។[២១]

ក៏ប៉ុន្តែធនាគារពិភពលោកបានកត់សម្គាល់ថា ត្រឹមខែវិច្ឆិកា ឆ្នាំ២០១៤ ប្រជាពលរដ្ឋ ១.៧៦២ គ្រួសារប៉ុណ្ណោះ (ឬក៏ ៥៧ ភាគរយ នៃអ្នកទទួលបានដីកសិកម្មបានធ្វើការបង្កបង្កើនផលនៅលើដីរបស់ខ្លួន ហើយត្រឹមតែ ៤១ ភាគរយនៃដីកសិកម្ម សរុបត្រូវបានបង្កបង្កើនផល។[២២] តាមការស៊ើបអង្កេតរបស់អង្គការ លីកាដូ ឃើញថា អត្រានៃភាពជោគជ័យមានកម្រិតទាបជាងនេះទៅទៀត។

នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចចំនួន ៧ ក្នុងចំណោមទីតាំងដីសម្បទានសង្គមកិច្ចទាំង ៨ ដែលគាំទ្រដោយគម្រោងបែងចែកដីដើម្បីសង្គមកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) ភាគច្រើននៃអ្នករស់នៅទីនោះ ដែលត្រូវបានសម្ភាសដោយអង្គការ លីកាដូ បានប្រាប់មកអង្គការ លីកាដូ ថាគាត់ជួបប្រទះការលំបាកជាច្រើននៅក្នុងការប្រើប្រាស់ដីកសិកម្មនេះ ហើយដូច្នេះមិនអាចរស់នៅដោយពឹងផ្អែកលើផលពីដីស្រែចំការដែលគាត់ទទួលបាននោះទេ។ គ្រប់គ្រួសារដែលត្រូវបានសម្ភាសនៅទីតាំងដីសម្បទានសង្គមកិច្ចទាំង ៧ នេះ បានអះអាងថាគាត់មានការដឹងគុណ ដោយសារតែមានដីលំនៅឋានជាកម្មសិទ្ធិផ្ទាល់ខ្លួននាពេលនេះ ប៉ុន្តែប្រជាពលរដ្ឋទាំងនោះជាច្រើនបានអះអាងបន្ថែមថា ពួកគេនៅតែមិនអាចធ្វើឲ្យជីវភាពរបស់គាត់ប្រសើរឡើងនៅឡើយនោះទេ ដោយសារគាត់មិនអាចបង្កបង្កើនផលនៅលើដីស្រែចំការរបស់គាត់ឲ្យបានត្រឹមត្រូវនៅឡើយ។ ហេតុដូច្នេះគាត់នៅតែជួបប្រទះបញ្ហាសន្តិសុខស្បៀងដដែល។

ជាឧទាហរណ៍ អ្នកទទួលបានដីម្នាក់នៅឃុំចង្រៀង ក្នុងខេត្តក្រចេះ បានប្រាប់អង្គការ លីកាដូ កាលពីខែកុម្ភៈ ឆ្នាំ២០១៥ ថា ទិន្នផលស្រូវដែលបានពីការបង្កបង្កើនផលលើផ្ទៃដី ដែលបានចែកឲ្យអាចផ្គត់ផ្គង់គ្រួសារគាត់បានត្រឹមតែរយៈពេល ៣ ខែ ប៉ុណ្ណោះ ក្នុង ១ ឆ្នាំ ដោយសារតែដីមិនសូវមានជីជាតិ និងការមិនមានលទ្ធភាពក្នុងការរានសំអាតដីទាំងអស់។ អ្នកលក់ដូរនៅតាមផ្លូវនៅក្នុងឃុំទីពោ (ទីពោ១) ម្នាក់បានអះអាងថា អ្នកភូមិនៅទីនោះ ខ្វះខ្វះខាតគ្រប់បែបយ៉ាង រួមទាំងអង្ករផងហើយត្រូវជំពាក់គេហើយសងគេនាពេលក្រោយ។

ដីកសិកម្មដែលត្រូវបានចែកជូន មានទំហំចន្លោះពីមួយទៅបីហិកតាកន្លះ[២៣] ដោយអាស្រ័យទៅលើទំហំគ្រួសារ។ នៅក្នុងឆ្នាំ ២០០៨ អង្គការកម្មវិធីស្បៀងអាហារពិភពលោកបានកត់សម្គាល់ថា ទំហំដីទាំងនេះ គឺសមល្មមក្នុងការផ្តល់ទិន្នផលស្រូវគ្រប់គ្រាន់សម្រាប់ការទ្រទ្រង់ជីវភាពគ្រួសារកម្រិតមធ្យមនៅជនបទ។[២៤] ក៏ប៉ុន្តែ អ្នកដែលរស់នៅលើដីសម្បទានសង្គមកិច្ចទាំងនោះហើយដែលយើងបានសម្ភាសបានផ្តល់នូវហេតុផលសំខាន់ចំនួនបី ដែលជាកត្តាធ្វើឲ្យប្រជាពលរដ្ឋមិនអាចបង្កបង្កើនផលលើដីទាំងនោះ ឲ្យបានពេលលេញត្រឹម

[១៩] ទីតាំងដីសម្បទានសង្គមកិច្ចពីរដែលស្ថិតនៅជិតគ្នា គឺសំបុក និងចង្រ្កង់ មានអត្រាតាំងទីលំនៅមធ្យម។ អ្នកភូមិម្នាក់បានប៉ាន់ប្រមាណថា ប្រជាពលរដ្ឋប្រហែល ៣០០ គ្រួសាររស់នៅលើទីតាំងទាំងពីរនេះ (អត្រាតាំងទីលំនៅប្រហែល ៥០ ភាគរយ)។ អង្គការលីកាដូ បានធ្វើការវិភាគរូបភាពរបស់ផ្កាយរណបកាលពីខែកុម្ភៈ ឆ្នាំ២០១៤ ហើយអាចធ្វើការសម្គាល់នូវគ្រោងផ្ទះចំនួន៣៦០ នៅលើដីលំនៅឋាននៃទីតាំងទាំងពីរ។ អត្រាតាំងទីលំនៅនៅទីតាំងសាកល្បងទី៤ នៅទីពោ១ ក្នុងខេត្តកំពង់ធំ មានកម្រិតទាបបើប្រៀបធៀបជាមួយកន្លែងដទៃទៀត នាពេលដែលក្រុងការងារអង្គការលីកាដូ បានធ្វើទស្សកិច្ច ដោយសារដីមិនសូវមានជីជាតិ។ ផ្ទុយទៅវិញ ទីតាំងដីសម្បទានសង្គមកិច្ចនៅឃុំជាំក្រវៀន ក្នុងខេត្តត្បូងឃ្មុំ ដីមានជីជាតិល្អ ហើយអត្រាតាំងទីលំនៅមានកម្រិតខ្ពស់ប្រហែល ៩០ ភាគរយ។

[២០] សូមមើលរបាយការណ៍ស្តីពីស្ថានភាពគម្រោង LASED របស់ធនាគារពិភពលោកចេញផ្សាយកាលពីខែធ្នូ ឆ្នាំ២០១៤ ទំព័រ ៤ សូចនាករនៃការអភិវឌ្ឍគម្រោង "យ៉ាងតិចណាស់ ៦០% នៃអ្នកទទួលបានដីមានភាពរីកចម្រើនជាងមុន ក្នុងការអនុវត្តប្រព័ន្ធគ្រប់គ្រងដី និងប្រព័ន្ធផលិតផលិតផលកសិកម្ម"។ សូមមើលព័ត៌មានបន្ថែមដែលមាននៅលើគេហទំព័រ http://www.worldbank.org/projects/P084787/land-allocation-social-economic-development?lang=en

[២១] ឯកសារស្តីពីគម្រោង LASED របស់ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ)។

[២២] របាយការណ៍ស្តីពីស្ថានភាពគម្រោងរបស់ធនាគារពិភពលោក ខែធ្នូ ឆ្នាំ២០១៤។

[២៣] ឯកសារស្តីពីគម្រោង LASED របស់ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ)។

[២៤] សូមមើលរបាយការណ៍អង្គការស្បៀងអាហារពិភពលោក "ប្រទេសកម្ពុជា៖ ការវិភាគស៊ីជម្រៅអំពីភាពងាយរងគ្រោះ និងសន្តិសុខស្បៀង" ខែធ្នូ ឆ្នាំ២០០៨ ទំព័រ ១២ ដែលមាននៅលើគេហទំព័រ http://www.wfp.org/content/cambodia-comprehensive-food-security-and-vulnerability-analysis-2008

ត្រូវ៖ ទីមួយគឺដីសម្បូរដោយខ្សាច់និងក្រួស ដីមិនសូវមានជីជាតិ និងខ្វះខាតទឹកសម្រាប់ស្រោចស្រប ទីពីរគឺមិនមានលទ្ធភាពធ្វើការសំអាត និងរៀបចំដីដែលមានព្រៃនៅឡើយដោយសារកង្វះខាតកំលាំងមនុស្ស និងឧបករណ៍ ហើយទីបី គឺដីកន្លែងខ្លះ នៅមានជម្លោះជាមួយប្រជាពលរដ្ឋ ដែលមិនមែនជាអ្នកទទួលបានសម្បទានដីសង្គមកិច្ច។

## គុណភាពដីទាប

អ្នកភូមិជាច្រើននាក់ នៅស្ទើរតែគ្រប់ទីតាំងដីសម្បទានសង្គមកិច្ចបានត្អូញត្អែរអំពីដីមិនសូវមានជីជាតិ។ កត្តានេះបានធ្វើឲ្យមានមន្ទិលយ៉ាងខ្លាំង ចំពោះប្រសិទ្ធិភាពនៃនីតិវិធីនៃការធ្វើអត្ត-សញ្ញាណកម្ម ដីដែលរួមបញ្ចូលទាំងការវាយតម្លៃទៅលើភាពសមស្របនៃដីកសិកម្ម។[២៥] គុណភាពដីនៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចក្នុងឃុំទីពោ ខេត្តកំពង់ធំ គឺស្ថិតក្នុងចំណោមដីដែលមិនសូវមានគុណភាពបំផុត ដោយដីមួយផ្នែកធំនៃដីស្រែចំការដែលត្រូវបានបែងចែកនោះមានលក្ខណៈស្ងួតសម្បូរក្រួសនិងខ្សាច់ ហើយខ្វះប្រព័ន្ធធារាសាស្ត្រស្រោចស្របដំណាំ។ អ្នកភូមិជាច្រើនដែលរស់នៅទីតាំងនេះ បាននិយាយថា ដំណាំបានផ្តល់ទិន្នផលបន្តិចបន្តួច សូម្បីតែមានជីជាតិច្រើននោះទេ។ ការរាយការណ៍បែបនេះ មិនមានជារឿងប្លែកនោះទេ ប្រសិនបើពិចារណាទៅលើការស្រាវជ្រាវ ដែលបានធ្វើការសិក្សាទៅលើទីតាំងដីសម្បទានសង្គមកិច្ចរបស់គម្រោង LASED នៅឃុំសំបុក និងចង្រ្កៀង នៅចន្លោះឆ្នាំ២០០៨ និង២០១២ ដែលបានកត់សម្គាល់ឃើញថា "យោងតាមការវិភាគទៅលើប្រព័ន្ធអេកូឡូស៊ីកសិ-កម្មដែលធ្វើឡើងក្នុងឆ្នាំ២០០៦ ដោយទីប្រឹក្សាបរទេស និងអាជ្ញាធរមូលដ្ឋានរបស់កម្ពុជា ៧០ ភាគរយនៃដីសម្បទានសង្គមកិច្ចនេះ គឺមានទៅដោយខ្សាច់និងដីឥដ្ឋ រួមជាមួយជម្រៅដីរាក់ខ្លាំង ហើយមិនសូវសមស្របសម្រាប់កសិកម្មនោះទេ"។[២៦]

មានតែករណីលើកលែងមួយប៉ុណ្ណោះ ពាក់ព័ន្ធនឹងគុណ-ភាពដី និងការប្រើប្រាស់ដីកសិកម្ម គឺនៅទីតាំងដីសម្បទានសង្គមកិច្ចនៅក្នុងឃុំជាំក្រវៀន នៃខេត្តត្បូងឃ្មុំ (អតីតខេត្តកំពង់ចាម)។ ទីតាំងនេះ (ជាទីតាំងដែលមានអ្នកទទួលបានដីធ្លីចំនួនតិចជាងគេបំផុត) ស្ថិតនៅក្នុងទីតាំងដែលត្រូវបានចាត់ថ្នាក់ជាទីតាំងដែលមានសកម្មភាពកសិកម្មខ្ពស់ ដោយដីមានជីជាតិសមរម្យ និងនៅជិតអូរ។ បន្ទាប់ពីគម្រោងធានាបាននូវការបោសសំអាតគ្រាប់មិនទាន់ផ្ទុះរួចរាល់មកដីនៅទីតាំងនេះមានលក្ខណៈងាយស្រួល ក្នុងការបង្កបង្កើនផល ហើយអ្នកភូមិជាច្រើនបានរាយការណ៍ថាដីទាំងនោះបានផ្តល់ទិន្នផលដំណាំដំឡូងមីបានខ្ពស់ល្អ។ អ្នកទទួលបានដីធ្លីជាច្រើននាក់បានប្រាប់អង្គការ លីកាដូ ថាស្ថានភាពសន្តិសុខស្បៀងរបស់គាត់មានភាពប្រសើរជាងមុន ហើយប្រជាពលរដ្ឋដែលរស់នៅទីនោះភាគច្រើន ទទួលបានប្រភពចំណូលចំបងរបស់គាត់ពីការធ្វើស្រែចំការ។ មិនមានអ្វីភ្ញាក់ផ្អើលទេ ទីតាំងនេះជាទីតាំងដែលមានអត្រានៃការតាំងទីលំនៅខ្ពស់បំផុតក្នុងចំណោមទីតាំងគម្រោង LASED ទាំង ៨ ទីតាំង ដែលមានប្រជាពលរដ្ឋប្រមាណពី ២២០ ទៅ ២៣០ គ្រួសារ (ប្រមាណ ៩០% នៃអ្នកដែលទទួលបានដីទាំងអស់) នៅបន្តរស់នៅលើដីនោះ។



ដីល្បាយខ្សាច់នៅក្នុងដីស្រែក្នុងទីតាំងដីសម្បទានសង្គមកិច្ច តំបន់ទីពោ១ ឃុំទីពោ ខេត្តកំពង់ធំ កាលពីខែតុលា ឆ្នាំ២០១៤

ដំណាំដែលធន់នឹងភាពរាំងស្ងួតខ្លាំងដូចជា ដំឡូងមី។ យោងតាមពលរដ្ឋដែលត្រូវបានសម្ភាសដោយអង្គការ លីកាដូ នៅទីតាំងដីសម្ប-ទានសង្គមកិច្ចទាំងពីរមានតែប្រជាពលរដ្ឋចំនួនតិចតួចប៉ុណ្ណោះដែលទទួលបានដីនៅឃុំទីពោអាចដាំដំណាំ លើដីស្រែចំការបានត្រឹមត្រូវ។ អ្នកទទួលបានដីធ្លីភាគច្រើនពឹងផ្អែកលើប្រភពចំណូលផ្សេងទៀតជាពិសេសការងារតាមរដូវឲ្យម្ចាស់ដីស្រែចម្ការ ដែលនៅក្បែរនោះ។

នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចក្នុងខេត្តក្រចេះ អ្នកភូមិជាច្រើនក៏បានរាយការណ៍ផងដែរថា យ៉ាងតិចណាស់មួយផ្នែកនៃដីកសិកម្មដែលបានបែងចែក គឺជាដីដែលសម្បូរទៅដោយថ្ម និងមិនសូវ

[២៥]សូមមើលឯកសារស្តីពីការវាយតម្លៃគម្រោងរបស់ធនាគារពិភពលោកឆ្នាំ២០០៨ ទំព័រ២០ "ការស្វែងរកដីដែលមានគុណភាព ជាផ្នែកមួយពិតប្រាកដនៃដំណើរការដំបូងនៃការធ្វើអត្តសញ្ញាណកម្មដី"។

[២៦] អេនឌ្រៀល នីហ្វ និងអ្នកដទៃទៀត"នយោបាយ និងក្រមសីលធម៌នៃសម្បទានដីនៅជនបទរបស់កម្ពុជា" ក្រមសីលធម៌កសិកម្ម និងបរិស្ថាន" ទស្សនាវដ្តីខែធ្នូ ឆ្នាំ២០១៣ វ៉ុល ២៦ ចេញផ្សាយ ៦ ទំព័រ១០៩៦ ដែលមាននៅលើគេហទំព័រ http://link.springer.com/article/10.1007%2Fs10806-013-9446-y



ប្រជាពលរដ្ឋដែលទទួលបានដីសម្បទានសង្គមកិច្ចព្យាយាមដាំដំលូងមីនៅលើដីខ្សាច់ ក្នុងទីតាំងទីពោ១ ឃុំទីពោ ខេត្តកំពង់ធំ កាលពីខែតុលា ឆ្នាំ២០១៤

## ការមិនមានសមត្ថភាពក្នុងការរៀបចំដីសម្រាប់ដាំដុះ

អ្នកទទួលបានដីសម្បទានសង្គមកិច្ចជាច្រើន នៅក្នុងខេត្តក្រចេះ បានប្រាប់អង្គការ លីកាដូ បន្ថែមទៀតថា អ្នកទាំងនោះមិនអាចបង្កបង្កើនផលលើដីស្រែចំការ ដែលពួកគេទទួលបានទាំងស្រុងបាននោះទេ ពីព្រោះដីមួយផ្នែកធំនៅតែគ្របដណ្ដប់ទៅដោយព្រៃវិចវិល ហើយអ្នកដែលទទួលបានដីខ្វះខាតមធ្យោបាយក្នុងការឆ្ការសំអាតដីទាំងនោះ។ អ្នកភូមិដែលត្រូវបានសម្ភាសនៅក្នុង៥ទីតាំងក្នុងខេត្តក្រចេះ ស្ទើរតែទាំងអស់បានរាយការណ៍ថា គម្រោងនេះត្រឹមតែបានជួយកាប់ឆ្ការសំអាត និងរៀបចំដីចំនួន ០,៥ ហិកតា ប៉ុណ្ណោះក្នុងដីកសិកម្មមួយប្លង់ ដោយមិនគិតពីទំហំសរុបនៃដីកសិកម្មក្នុងមួយប្លង់នោះទេ។ ការឆ្ការសំអាត និងរៀបចំដីដែលនៅសល់ត្រូវទុកជាបន្ទុករបស់អ្នកទទួលបានដី ដែលកត្តានេះធ្វើឲ្យអ្នកទាំងនោះ ជាធម្មតាមិនមានលទ្ធភាពក្នុងការធ្វើនោះទេ។[២៧]

ជាលទ្ធផល ជាក់ស្ដែងគ្រួសារដែលត្រូវបានទទួលបានដីជាច្រើននាក់ ពី១ ទៅ ៣,៥ ហិកតា បានដីត្រឹមតែ ០,៥ ហិកតា ប៉ុណ្ណោះទេសម្រាប់ការបង្កបង្កើនផល។ ចំនួននេះត្រូវបានចាត់ទុកថាមិនគ្រប់គ្រាន់សម្រាប់ការចិញ្ចឹមគ្រួសារកម្រិតមធ្យមមួយ នៅជនបទក្នុងប្រទេសកម្ពុជាបានទេ។[២៨] មេភូមិម្នាក់នៅក្នុងដីសម្បទានសង្គមកិច្ចក្នុងឃុំសំបុក ខេត្តក្រចេះ បានប្រាប់អង្គការ លីកាដូ ថា អ្នកភូមិជាច្រើនត្រូវបានគេបន្ទោសថា មានភាពខ្ជិលច្រអូសក្នុងការកាប់ឆ្ការសំអាត និងបង្កបង្កើនផលលើដីស្រែចំការឲ្យបានត្រឹមត្រូវ។ ការចោទប្រកាន់នេះ ត្រូវបានលោកចាត់ទុកថា មិនយុត្តិធម៌ ដោយហេតុថាដីស្រែដែលត្រូវបានប្រគល់ឲ្យមានផ្នែកខ្លះជាដីសំបូរទៅដោយថ្ម ហើយមិនមានដីជាតិ ហើយអ្នកភូមិក្រីក្រមិនមានមធ្យោបាយក្នុងការរានឆ្ការសំអាត និងរៀបចំដីនោះទេ។

## ជម្លោះលើដីដែលបានចែកជូន

ក្នុងខែឧសភា ឆ្នាំ២០០៩ ប្រជាពលរដ្ឋចំនួន ១៣០ គ្រួសារត្រូវជម្លៀសចេញដីធ្លី ដោយខ្លះរងការបណ្ដេញចេញដោយបង្ខំ ដើម្បីយកដីសម្រាប់ទីតាំងសម្បទានដីសង្គមកិច្ចក្នុងឃុំសំបុក និងឃុំចង្ក្រៀង ក្នុងខេត្តក្រចេះ។ នាពេលនោះដែរ មានការរាយការណ៍ថា អ្នកដែលត្រូវបានគេតម្រូវឲ្យចាកចេញ បានរស់នៅទីនោះតាំងពីឆ្នាំ២០០១ មកម្លេះ។[២៩]

ជម្លោះនៃការកាន់កាប់ដី ដែលកើតមានលើដីកសិកម្មដែលត្រូវបានបែកចែកឲ្យ ត្រូវបានអះអាងថា ជាហេតុផលសំខាន់មួយដែលធ្វើឲ្យលទ្ធភាពក្នុងការប្រើប្រាស់ដីកសិកម្មនៅមានកម្រិត ចំពោះទីតាំងដីសម្បទានសង្គមកិច្ចចំនួន ២ កន្លែងផ្សេងទៀតនៅក្នុងខេត្តក្រចេះ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៥ ស្ត្រីម្នាក់ ដែលត្រូវបានសម្ភាសនៅក្នុងឃុំដារ ខេត្តក្រចេះ បាននិយាយថា គ្រួសាររបស់អ្នកស្រីបានផ្លាស់

[២៧] អ្នកភូមិម្នាក់នៅក្នុងដីសម្បទានសង្គមកិច្ច ក្នុងឃុំទីពោ បានប្រាប់អង្គការ លីកាដូ ថា នៅក្នុងឃុំនេះ គម្រោងបានជួយឆ្ការសំអាតដីស្រែឲ្យត្រឹមតែ ០,៥ ហិកតាប៉ុណ្ណោះ ប៉ុន្តែពួកគេអាចជួលគោយន្តដើម្បីរាស់សំអាតដីដែលនៅសល់។ គោយន្តមាននៅគ្រប់សហគមន៍ទាំងអស់ ហើយប្រាក់ឈ្នួលដែលត្រូវបង់សម្រាប់ជួលគោយន្ត គឺចូលទៅក្នុងកញ្ចប់មូលនិធិសហគមន៍។

[២៨] សូមមើល WFP 2008 ខាងលើ។ សូមមើល GTZ៖ “ការវិនិយោគផ្ទាល់របស់បរទេស (FDI) លើវិស័យដីធ្លីនៅក្នុងប្រទេសកម្ពុជា” ឆ្នាំ២០០៩ ទំព័រ១១ ដែលមាននៅលើគេហទំព័រ http://www2.gtz.de/dokumente/bib-2010/gtz2010-0061en-foreign-direct-investment-cambodia.pdf

[២៩] នូវ វណ្ណារិន “អាជ្ញាធរខេត្តក្រចេះចាប់ផ្ដើមរុះរើផ្ទះនៅលើដីសម្បទាន” ការសែតខេមបូឌា ដេលី ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៩ ដែលមាននៅលើគេហទំព័រ https://www.cambodiadaily.com/archives/kratie-officials-start-removal-of-homes-on-land-concession-64880/

## ករណីសិក្សា៖ ឃុំថ្មី

នៅតាមតំបន់ដីដែលគ្មានជីជាតិ នៃទីតាំងដីសម្បទានសង្គមកិច្ច ដែលស្ថិតនៅក្នុងឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះគេបានឃើញមានផ្ទះរាប់សិបខ្នង ដែលមិនទាន់សាងសង់រួច និងសម្ភារៈសាងសង់ជាច្រើនដែលមិនទាន់បានប្រើប្រាស់ ត្រូវបានទុកចោលគរលើគ្នាយ៉ាងរាយប៉ាយ ។ ទីតាំងដាច់ស្រយ៉ាលនេះ ដែលមានចម្ងាយ ២៣ គីឡូម៉ែត្រពីផ្លូវជាតិគួរតែជាតំបន់មួយដែលត្រូវមានការតាំងទីលំនៅរបស់ប្រជាពលរដ្ឋជាង ៣០០គ្រួសារ។ ក៏ប៉ុន្តែនៅពេលដែលអង្គការ លីកាដូ បានធ្វើដំណើរទៅដល់ទីកន្លែងនោះកាលពីខែកុម្ភៈ ឆ្នាំ២០១៥ ទីតាំងនោះមានប្រជាពលរដ្ឋចំនួនត្រឹមតែ ៣៣គ្រួសារប៉ុណ្ណោះដែលកំពុងរស់នៅ។

មានសាលារៀនថ្មីមួយដែលអត់មានសិស្សទៅរៀននៅឡើយនោះទេ គឺជាអាគារដ៏រឹងមាំស្រស់ស្អាត ព្រមទាំងមានបដាមួយសរសេថាការសាងសង់បានចាប់ផ្តើមតាំងពីឆ្នាំ ២០១២ ម្ល៉េះ ។ ប្រជាពលរដ្ឋដែលរស់នៅទីកន្លែងនោះបានឲ្យដឹងថា សាលារៀននៅតែបន្តបិទទ្វារ ហើយមិនមានគ្រូមកបង្រៀនទេ។ ក្រុមគ្រួសារទាំងអស់នោះ ដែលបានតាំងទីលំនៅនៅលើទីតាំងដីសម្បទានសង្គមកិច្ចនេះ ត្រូវសម្រេចចិត្តមិនបញ្ជូនកូនឲ្យទៅសាលារៀន ឬក៏ទុកឲ្យកូនៗទាំងនោះរស់នៅភូមិកំណើតរបស់អ្នកទាំងនោះទៅវិញ។ ក្រុមគ្រួសារមួយបានឲ្យអង្គការ លីកាដូ ដឹងថាអ្នកទាំងនោះបានផ្លាស់មករស់នៅនៅទីតាំងថ្មីនេះអស់រយៈពេលពីរឆ្នាំរួចមកហើយ ប៉ុន្តែកូនស្រីរបស់អ្នកទាំងនោះចំនួនពីរនាក់ ដែលម្នាក់មានអាយុ ៩ឆ្នាំ និងម្នាក់ទៀតមានអាយុ ១៣ឆ្នាំ នៅតែបន្តរស់នៅនៅក្នុងភូមិចាស់របស់អ្នកទាំងពីរ ដែលមានចម្ងាយប្រមាណ ៤គីឡូម៉ែត្រ ពីទីតាំងថ្មីនេះ ដើម្បីបន្តការសិក្សារបស់អ្នកទាំងពីរនេះ។ មានក្រុមគ្រួសារមួយផ្សេងទៀតបាននិយាយថា កូន ៤នាក់របស់អ្នកទាំងនោះស្នាក់នៅជាមួយនឹងជីដូនរបស់ពួកគេនៅភូមិចាស់។

ប្រជាពលរដ្ឋមួយចំនួនដែលត្រូវបានសម្ភាសដោយអង្គការ លីកាដូ បាននិយាយថា ក្រុមគ្រួសារ "មួយចំនួន" ក្នុងចំណោមគ្រួសារដែលបានមកតាំងទីលំ-នៅឋានថ្មីនេះ អាចធ្វើការដាំដុះលើដីស្រែចម្ការបាន ក៏ប៉ុន្តែក្រុមគ្រួសារមួយចំនួនទៀតមិនអាចដាំដុះបានលើដីស្រែចម្ការបាននោះទេ។ ការខ្វះខាតសម្ភារៈក្នុងការរៀបចំដីស្រែ គឺជាឧបសគ្គដ៏សំខាន់ ដោយសារតែផ្ទៃដីជាច្រើននៅតែបន្តគ្របដណ្តប់ទៅដោយព្រៃ។ ក្រុមគ្រួសារដែលបានតាំងទីលំនៅកន្លែងថ្មីនោះពឹងផ្អែកយ៉ាងខ្លាំងលើការចែកអង្ករ ការដោះដូរទំនិញ ការស្វែងរកអាហារនៅក្នុងព្រៃ ហើយក្រុមគ្រួសារមួយចំនួនប្រកបរបរចិញ្ចឹមជីវិតតាម-រយៈការដឹកឈើ និងកាប់ឈើ។ ស្ត្រីម្នាក់បានប្រាប់អង្គការ លីកាដូ ថានាងមិនបានទទួលការបណ្តុះបណ្តាលស្តីពីការធ្វើកសិកម្មអ្វីនោះទេ ប៉ុន្តែនាងត្រូវបានគេផ្តល់ឲ្យគ្រាប់ពូជដើម្បីដាំស្វាយ ដូង និងក្រូចឆ្មារ។ ប៉ុន្តែកូនឈើទាំងនោះ ត្រូវបានចែកឲ្យនៅក្នុងរដូវប្រាំង ហើយដំណាំទាំងអស់នោះបានងាប់មុនពេលរដូវវស្សាមកដល់ ដោយសារតែខ្វះខាតទឹកដើម្បីស្រោចលើដំណាំទាំងអស់នោះ។

ទៅរស់នៅនៅទីនោះនៅក្នុងឆ្នាំ២០១២។ ប៉ុន្តែរហូតមកទល់សព្វថ្ងៃ ពួកគេនៅតែមិនអាចបង្កបង្កើនផលលើដីកសិកម្ម ដែលបានសំអាតរួចរាល់ចំនួន ០,៥ ហិកតា នោះទេ ពីព្រោះអ្នកភូមិដែលមិនមែនជាអ្នកទទួលបានសម្បទានដីសង្គមកិច្ច បានកាន់កាប់ដីស្រែនោះរួចទៅហើយ តាំងពីពេលពួកគេបានមកដល់ទីតាំងនោះមកម្លេះ។ អ្នកស្រីបាននិយាយថា អ្នកស្រីបានស្នើសុំម្តងហើយម្តងទៀតដល់អាជ្ញាធរឲ្យជួយអ្នកស្រី ប៉ុន្តែមិនមានដំណោះស្រាយសម្រាប់អ្នកស្រីនោះទេ។ មេភូមិម្នាក់នៅក្នុងឃុំដារ បានអះអាងថា ជម្លោះលើដីស្រែគឺមានច្រើនដែលប៉ះពាល់ដល់ក្រុមគ្រួសារជាច្រើនគ្រួសារ ដែលទទួលបានប្លង់ដីកសិកម្មនៅព្រំប្រទល់ដីសម្បទានសង្គមកិច្ច។

### . . . ជម្លោះលើដីស្រែគឺមានច្រើនដែលប៉ះពាល់ដល់ក្រុមគ្រួសារជាច្រើនគ្រួសារ ដែលទទួលបានប្លង់ដីកសិកម្មនៅព្រំប្រទល់ដីសម្បទានសង្គមកិច្ច។

នៅក្នុងសន្និសីទប្រចាំឆ្នាំរបស់ធនាគារពិភពលោកឆ្នាំ២០១២ ស្តីពីដីធ្លីនិងភាពក្រីក្រ កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GTZ/GIZ) បានបង្ហាញនូវឯកសារស្តីពីគម្រោង LASED ដោយបានកត់សម្គាល់ថា ការរំលោភទន្ទ្រានពីមនុស្សជាច្រើនក្រុមផ្សេងៗគ្នា ដែលរួមមានមន្ត្រីឃោធា និងស្ថាប័នរដ្ឋនានាទៅលើដីដែលបានបែងចែក គឺពិតជាបញ្ហាប្រឈមមួយ ដែលបានកើតមានឡើងចាប់តាំងពីការចាប់ផ្តើមគម្រោងមកម្ល៉េះ។ ឯកសារបានសន្និដ្ឋានថា៖

"ការការពារពីការរំលោភទន្ទ្រានដីធ្លីដ៏មានប្រសិទ្ធិភាពតែមួយគត់ គឺជាការប្រើប្រាស់ជាក់ស្តែងលើដីធ្លីនោះ។ នៅពេលដែលដីធ្លីត្រូវបានចុះបញ្ជីហើយរួចរាល់សម្រាប់ការបែងចែកដីទាំងនោះ ត្រូវតែធ្វើការបែងចែកភ្លាមទៅឲ្យគ្រួសារនីមួយៗកាន់កាប់។ គ្រួសារទាំងនោះត្រូវតែទទួលយកដីរបស់ខ្លួនទៅកាន់កាប់ដោយមិនមានពន្យាពេល ហើយត្រូវចាប់ផ្តើមធ្វើការបង្កបង្កើនផលជាក់ស្តែងដើម្បីបង្ហាញថាដីទាំងនោះមានកម្មសិទ្ធិរួចហើយ។"[៣០]

នៅក្នុងទីតាំងសម្បទានដីសង្គមកិច្ច ដែលស្ថិតនៅដាច់ស្រយាលនៅក្នុងឃុំចំបក់ ខេត្តក្រចេះ ជម្លោះនៃការកាន់កាប់លើដីកសិកម្មក្លាយជាមូលហេតុមួយក្នុង



ដីលំនៅស្ថាននៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចក្នុងឃុំថ្មី ខេត្តក្រចេះ កាលពីខែកុម្ភៈ ឆ្នាំ២០១៥

[៣០] ឯកសាររបស់ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ) ទំព័រ៥។



ទីតាំងដីសម្បទានសង្គមកិច្ចដែលនៅដាច់ស្រយាលក្នុងឃុំចំបក់ ខេត្តក្រចេះ ជាកន្លែងដែលមានការកាប់ព្រៃ និងទំនាស់ដីធ្លីយ៉ាងខ្លាំងក្លា កាលពីខែកុម្ភៈ ឆ្នាំ២០១៥

ចំណោមមូលហេតុជាច្រើន ដែលធ្វើឲ្យមានគ្រួសារចំនួនតិចតួចប៉ុណ្ណោះបានទៅតាំងលំនៅ នៅទីនោះ(ក្រៅពីមូលហេតុមិនមានសាលារៀន និងមិនមានលទ្ធភាពក្នុងការឆ្ការសំអាតដីកសិកម្ម)។ អង្គការ លីកាដូ បានសម្ភាសគ្រួសារចំនួន ២ ក្នុងចំណោមគ្រួសារចំនួន ៧ ដែលបានទៅរស់នៅនៅក្នុងឃុំចំបក់ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៥ ហើយគ្រួសារទាំងពីរបានរាយការណ៍ថា ពួកគាត់មិនទាន់អាចបង្កបង្កើនផលលើដីដែលបានផ្តល់ឲ្យនោះទេ ដោយសារជម្លោះដីធ្លីមិនទាន់ត្រូវបានដោះស្រាយជាមួយអ្នកភូមិនៅក្បែរនោះ។ នៅទីនោះ អង្គការ លីកាដូ បាននិយាយជាមួយគ្រួសារមួយដែលមានជម្លោះលើដីកសិកម្មជាមួយអ្នកទទួលបានសម្បទានដីសង្គមកិច្ច។ គ្រួសារនោះបានអះអាងថា ពួកគេបានទិញដីប្រមាណ ៣ ហិកតាពីមនុស្សម្នាក់ដែលបានអះអាងថា ដីនោះមិនមែនជាដីរដ្ឋទេ តាំងពី ៣ ទៅ ៤ ឆ្នាំមុនមកម្លេះ។ ក្នុងឆ្នាំ២០១៣ ដីស្រែចំការរបស់គាត់ប្រមាណពាក់កណ្តាលត្រូវបានអាជ្ញាធរយក និងបែងចែកទៅឲ្យអ្នកដែលត្រូវទទួលបានសម្បទានដីសង្គមកិច្ច។ ការបាត់បង់ដីស្រែបានបង្កជាការគម្រាមកំហែងគួរឲ្យកត់សម្គាល់ទៅលើសន្តិសុខស្បៀង សម្រាប់គ្រួសារនោះ។

## សុវត្ថិភាពនៃភាពជាម្ចាស់កម្មសិទ្ធិមិនទាន់ត្រូវបានធានា

របាយការណ៍ចុងក្រោយបំផុត ស្តីពីស្ថានភាពនៃគម្រោង LASED របស់ធនាគារពិភពលោកបានអះអាងថា "សុវត្ថិភាពនៃភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លី គឺត្រូវបានចាត់ទុកថាជាអត្ថប្រយោជន៍ដ៏ធំបំផុតដែលទទួលបានពីគម្រោង។"[៣១] នៅក្នុងប្រទេសកម្ពុជាអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ចបានចែងថា អ្នកទទួលបានសម្បទានដីសង្គមកិច្ច មានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំប័ណ្ណកម្មសិទ្ធិដីក្នុងរយៈពេល ៥ឆ្នាំ បន្ទាប់ពីអ្នកទាំងនោះទទួលបានដីសម្បទាន។ ក៏ប៉ុន្តែ នៅក្នុងខែកុម្ភៈ ឆ្នាំ២០១៥ មេភូមិម្នាក់ និងអ្នកទទួលបានសម្បទានដីសង្គមកិច្ចជាច្រើននាក់នៅក្នុងឃុំសំបុក ខេត្តក្រចេះ បានរាយការណ៍មកអង្គការ លីកាដូ ថាអ្នកទាំងនោះនៅតែមិនទាន់ទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លី ទោះបីជាគាត់បានកាន់កាប់លើដីនោះអស់រយៈពេលជាង ៦ ឆ្នាំហើយក៏ដោយ។ ការស្នើសុំម្តងហើយម្តងទៀតដោយអ្នកភូមិសំបុកទៅកាន់អាជ្ញាធរកម្ពុជា ដើម្បីឲ្យអនុវត្តច្បាប់ និងផ្តល់នូវប័ណ្ណកម្មសិទ្ធិដីធ្លីមិនទាន់ត្រូវបានអនុវត្តតាមនោះទេ។ ដូចគ្នានេះដែរ នៅក្នុងឃុំចង្រៀង ខេត្តក្រចេះ ដែលនៅក្បែរនោះ អ្នកភូមិជាច្រើនដែលត្រូវបានសម្ភាសមិនបានដឹងថា មានអ្នកទទួលបានដីសម្បទានសង្គមកិច្ចណាម្នាក់ ដែលទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅឡើយទេ បើទោះបីជាតាមការរាយការណ៍ថា អ្នកទាំងនោះបានតាំងទីលំនៅនៅក្នុងទីតាំងនោះប្រមាណ ៦ឆ្នាំ មុននេះក៏ដោយ។

ដំណើរការនៃការផ្តល់ប័ណ្ណកម្មសិទ្ធិសម្រាប់អ្នកទទួលបានសម្បទានដីសង្គមកិច្ចត្រូវបានគេរាយការណ៍ថា កំពុងដំណើរការមួយរយៈ។ របាយការណ៍ស្តីពីស្ថានភាពនៃគម្រោង LASED របស់ធនាគារពិភពលោក ដែលត្រូវបានចេញផ្សាយកាលពីចុងឆ្នាំ២០១៣ បានអះអាងថា៖ "ដោយអ្នកទទួលបានដីមួយចំនួនបានកាន់កាប់ដីអស់រយៈពេល ៥ឆ្នាំហើយមកដល់ឥឡូវ ដូចនេះគម្រោងនេះបានចាប់ផ្តើមដំណើរការក្នុងការផ្តល់ប័ណ្ណកម្មសិទ្ធិ។ ប័ណ្ណកម្មសិទ្ធិដីគួរតែត្រូវបានប្រគល់ដល់អ្នកទាំងនោះនៅចុងឆ្នាំ២០១៣។"[៣២] ការអះអាងដូចគ្នាក៏មាននៅក្នុងរបាយការណ៍ ស្តីពីស្ថានភាពនៃគម្រោងលើកក្រោយទៀត ដែលបានចេញផ្សាយកាលពីពាក់កណ្តាលឆ្នាំ២០១៤ ដែលថាប័ណ្ណកម្មសិទ្ធិដីនឹងត្រូវចែកជូននៅចុងឆ្នាំ២០១៤។[៣៣] ការ

[៣១] របាយការណ៍ស្តីពីស្ថានភាពគម្រោងរបស់ធនាគារពិភពលោក ចេញផ្សាយខែធ្នូ ឆ្នាំ២០១៤ ទំព័រ ២។
[៣២] របាយការណ៍ស្តីពីស្ថានភាពគម្រោងរបស់ធនាគារពិភពលោក ចេញផ្សាយខែធ្នូ ឆ្នាំ២០១៣ ទំព័រ ៧ ដែលមាននៅលើគេហទំព័រ http://documents.worldbank.org/curated/en/2013/12/18622843/cambodia-land-allocation-socialeconomic-development-p084787-implementation-status-results-report-sequence-07
[៣៣] របាយការណ៍ស្តីពីស្ថានភាពគម្រោងរបស់ធនាគារពិភពលោក ចេញផ្សាយខែមិថុនា ឆ្នាំ២០១៤ ទំព័រ ៧ ដែលមាននៅលើគេហទំព័រ http://documents.worldbank.org/curated/en/2014/06/19743598/cambodia-land-allocation-social-economicdevelopment-p084787-implementation-status-results-report-sequence-08

ពន្យាពេលនេះ បានធ្វើឲ្យអ្នកទទួលបានសម្បទានដីសង្គមកិច្ចនៅក្នុងឃុំសំបុក និងចង្រៀង ជួបហានិភ័យក្នុងការបាត់បង់ដីធ្លីរបស់ខ្លួន។

លើសពីនេះទៅទៀតអ្នកទទួលបានដីនៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចថ្មីជាច្រើនក្រោមគម្រោង LASED ប្រហែលជាមិនអាចបំពេញតាមលក្ខខណ្ឌ ដើម្បីអាចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីបានបន្ទាប់ពីរយៈពេល ៥ឆ្នាំមកទេ។ បើទោះជាអង្គការ លីកាដូ មិនអាចទទួលបានឯកសារថតចម្លងនៃកិច្ចសន្យា ដែលបានចុះហត្ថលេខាដោយអ្នកទទួលបានដីក៏ដោយ ក៏លក្ខខណ្ឌជាច្រើនសម្រាប់ម្ចាស់កម្មសិទ្ធិត្រូវបានដាក់បង្ហាញជាសាធារណៈ នៅក្នុងទីតាំងសម្បទានសង្គមកិច្ច រួមមានលក្ខខណ្ឌតម្រូវឲ្យអ្នកទទួលបានដីធ្លី "ដាំដុះដំណាំលើដីស្រែចំការ" ហើយត្រូវតែបាន "សាងសង់ទីលំនៅ និងត្រូវកំពុងរស់នៅលើដីលំនៅឋាននោះ។" លុះត្រាតែបានកាន់កាប់ដីធ្លីអស់រយៈពេល ៥ ឆ្នាំមក ទៅតាមលក្ខខណ្ឌដែលបានរៀបរាប់ខាងលើទើបអ្នកទទួលបានដីធ្លី អាចដាក់ពាក្យសុំប័ណ្ណកម្មសិទ្ធិដីធ្លីនោះបាន។ ប្រសិនបើអ្នកទទួលបានដីធ្លីខកខានក្នុងការបំពេញនូវលក្ខខណ្ឌទាំងនេះ រដ្ឋនឹងរឹបអូសយកដីមកវិញ។ លក្ខខណ្ឌទាំងនេះ គឺស្របទៅតាមបទបញ្ញត្តិដែលមាននៅក្នុងអនុក្រឹត្យលេខ ១៩ ស្តីពីសម្បទានដីសង្គមកិច្ច។[៣៤]

តាមការតាមដានមើលរបស់អង្គការ លីកាដូ ដោយសារតែអត្រានៃការតាំងទីលំនៅ និងការប្រើប្រាស់ដីកសិកម្មមានកម្រិតទាបនៅចុងឆ្នាំ២០១៤ និងដើមឆ្នាំ២០១៥ អ្នកទទួលបានដីធ្លីជាច្រើនអាចប្រឈមមុខនឹងហានិភ័យក្នុងការខកខានលើការបំពេញ ទៅតាមលក្ខខណ្ឌទាំងនេះ ដោយសារតែការអនុវត្តគម្រោងនៅមិនទាន់បានល្អនៅឡើយ។ សុវត្ថិភាពនៃភាពជាម្ចាស់កម្មសិទ្ធិ គឺមិនត្រូវបានធានាសម្រាប់អ្នកទទួលបានដីមួយផ្នែកធំ ក្នុងចំណោមអ្នកទទួលបានដីធ្លីជាង ៣.០០០ គ្រួសារ ក្រោមគម្រោង LASED នោះទេ។



តំបន់លំនៅស្ថានក្នុងទីតាំងដីសម្បទានសង្គមកិច្ចក្នុងឃុំសំបុក រូបភាពពី © Google StreetView
កាលពីខែវិច្ឆិកា ឆ្នាំ២០១៣

**កាលបរិច្ឆេទនៃការចុះបញ្ជី និងចំនួនគ្រួសារដែលទទួលបានដីនៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចទាំង៨ កន្លែង ក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច[៣៥]**

| តំបន់ដីសម្បទានសង្គមកិច្ចក្នុងគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច | កាលបរិច្ឆេទនៃការចុះបញ្ជី* | ចំនួនគ្រួសារទទួលបានដី** |
|---|---|---|
| ឃុំសំបុក ស្រុកចិត្របូរី ខេត្តក្រចេះ | ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ | ៥៥៤ |
| ឃុំចង្ក្រាន ស្រុកចិត្របូរី ខេត្តក្រចេះ | ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ | ៣៣១ |
| ឃុំដារ ស្រុកចិត្របូរី ខេត្តក្រចេះ | ថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៧ | ៤០២ |
| ឃុំថ្មី ស្រុកចិត្របូរី ខេត្តក្រចេះ | ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១២ | ៤៣២ |
| ឃុំចំបក់ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ | ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ | ៤០០ |
| ឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ | ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៧ | ២៥០ |
| ទីពោ១ ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ | ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ | ៤៧៩ |
| ទីពោ២ ឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ | ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ | ៣០០ |

* ការចុះបញ្ជីជាដីឯកជនរបស់រដ្ឋ គឺចាំបាច់ណាស់មុនពេលការបែងចែកទៅដល់អ្នកដែលត្រូវទទួលដីសម្បទានសង្គមកិច្ច។

** រួមបញ្ចូលទាំងដីលំនៅឋាន ឬដីកសិកម្ម។ ក្រោមរួមបញ្ចូលទាំងអ្នកដែលត្រូវទទួលបានដីលំនៅឋាន និង/ឬ ដីកសិកម្ម។ នៅក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ប្រជាពលរដ្ឋចំនួន ៧៤គ្រួសារ ទទួលបានដីលំនៅឋាន ៦៥៨គ្រួសារបានទទួលដីកសិកម្ម និងប្រជាពលរដ្ឋចំនួន ២.៤១៦គ្រួសារបានទទួលទាំងដីកសិកម្ម និងដីលំនៅឋាន។

[៣៤] មាត្រា ២៦ នៃអនុក្រឹត្យស្តីពីដីសម្បទានសង្គមកិច្ច លេខ ១៩ អនក/បក/ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ដែលមាននៅលើគេហទំព័រ http://www.cambodiainvestment.gov.kh/sub-decree-19-on-social-land-concessions_030319.html

[៣៥] ទិន្នន័យយកចេញពីរបាយការណ៍ស្តីពីស្ថានភាពគម្រោងរបស់ធនាគារពិភពលោក ចេញផ្សាយខែធ្នូ ឆ្នាំ២០១៤ ទំព័រ ៦ និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDDS) គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍន៍សេដ្ឋកិច្ច (LASED) លក្ខខណ្ឌអនុវត្ត (ToR) ការវាយតម្លៃចុងបញ្ចប់នៃគម្រោង ដែលមាននៅលើគេហទំព័រ
http://www.ncdd.gov.kh/images/job/2014/Aug/LASED%20-%20TOR%20re%20End-Project%20Evaluation%20%28v%20Bank%20inputs%20120814%29_Final.pdf



កំណាត់ឈើតំរៀបគ្នាជាជួរតាមផ្លូវទៅកាន់ដីលំនៅស្ថានក្នុងទីតាំងដីសម្បទានសង្គមកិច្ចទីពោ១ ស្ថិតក្នុងឃុំទីពោ ខេត្តកំពង់ធំ កាលពីខែតុលា ឆ្នាំ២០១៤

## ករណីសិក្សា៖ ឃុំទីពោ

មានតំបន់ដីសម្បទានសង្គមកិច្ចចំនួនពីរកន្លែងដែលនៅជិតគ្នា នៅចំណុចកណ្តាលរវាងតំបន់សម្បទានដីសេដ្ឋកិច្ចក្នុងឃុំទីពោ ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលអង្គការ លីកាដូ បានធ្វើដំណើទៅដល់កាលពីខែតុលា ឆ្នាំ២០១៤។ នៅតំបន់ទី១ (ទីពោមួយ) អង្គការ លីកាដូ បានសម្ភាសស្ត្រីម្នាក់ឈ្មោះ លីណា (មិនមែនជាឈ្មោះពិតរបស់អ្នកស្រីទេ) ក្នុងចំណោមអ្នកដែលត្រូវបានសម្ភាសផ្សេងទៀត។ លីណា បានបើកហាងលក់ដូរមួយនៅតាមបណ្តោយផ្លូវក្នុងភូមិ។ លីណា បានផ្លាស់ទីលំនៅទៅរស់នៅតំបន់ដីសម្បទានសង្គមកិច្ចក្នុងឃុំទីពោមួយអស់រយៈពេល ៤ឆ្នាំមកហើយ។ ក្រៅពីបានទទួលដីសម្ប-ទានសម្រាប់តាំងលំនៅឋានដែលមានទំហំចំនួន ៤០ម x ៣០ម អ្នកស្រីបានទទួលដីសម្បទានទំហំ ២ហិចតាកន្លះទៀតសម្រាប់ធ្វើស្រែចំការ។

ប៉ុន្តែ ដីស្រែដែលត្រូវបានបែងចែកទៅដល់អ្នកស្រី គឺជាប្រភេទដីល្បាយខ្សាច់ហើយអ្នកស្រីមិនអាចដាំដំណាំលើដីនោះបានឡើយ។ លីណា ដែលជាស្ត្រីមេម៉ាយ និងកូនប្រុសចំនួន ២នាក់របស់អ្នកស្រី (ដែលម្នាក់មានអាយុ ២១ឆ្នាំ ហើយម្នាក់ទៀតអាយុ ១៧ឆ្នាំ) បានព្យាយាមដាំដំណាំលើដីស្រែនោះតែពុំទទួលបានផលអ្វីសោះ មូលហេតុនេះហើយធ្វើកូនទាំងពីរនេះបានចាកចេញពីកន្លែងនោះ។ ម្នាក់បានព្យាយាមទៅរកការងារធ្វើនៅប្រទេសថៃ ប៉ុន្តែរកមិនបាន ហើយបច្ចុប្បន្នរស់នៅក្នុងក្រុងប៉ោយប៉ែត។

អ្នកស្រី លីណា បានមានប្រសាសន៍ថា អ្នកដែលទទួលបានដីសម្បទានមួយចំនួនក្នុងឃុំទីពោ បានដាំដើមដំឡូងមី ប៉ុន្តែអ្នកដែលទទួលបានដីសម្បទានផ្សេងទៀតមិនបានធ្វើការដាំដុះដំណាំលើដីស្រែរបស់ខ្លួនឡើយ។ អ្នកភូមិតែងតែទៅធ្វើការជាកម្មករសម្អាតស្មៅដោយគិតប្រាក់កម្រៃតាមថ្ងៃនៅដីស្រែចម្ការក្បែរៗនោះ។ អ្នកទទួលបានដីសម្បទានមួយចំនួនទៀតធ្វើការឲ្យក្រុមហ៊ុនវៀតណាម ដែលទទួលបានដីសម្បទានសេដ្ឋកិច្ចសម្រាប់ដំណាំកៅស៊ូនៅក្បែរនោះ ហើយអ្នកមួយចំនួនផ្សេងទៀតបម្រើការងារឲ្យក្រុមហ៊ុនចម្ការកៅស៊ូផ្សេងទៀតដែលស្ថិតនៅក្បែរៗនោះដែរ។ ការងារទាំងនោះគឺមិនមានលក្ខណៈទៀងទាត់នោះទេ ទាំងនៅតាមបណ្តាក្រុមហ៊ុននានានិងតាមបណ្តាដីស្រែចម្ការតូចៗមួយចំនួន។ យោងតាមប្រសាសន៍របស់អ្នកស្រីលីណា ប្រជាពលរដ្ឋភាគច្រើនចូលចិត្តធ្វើការងារនៅតាមដីស្រែចម្ការតូចៗជាជាងធ្វើការឲ្យក្រុមហ៊ុន ដោយសារតែក្រុមហ៊ុនផ្តល់ប្រាក់ជាប្រចាំខែ ឯដីស្រែចម្ការតូចៗផ្តល់ប្រាក់ប្រចាំថ្ងៃ។ អត្រាប្រាក់កម្រៃប្រចាំថ្ងៃនៅពេលដែលមានការងារធ្វើគឺចំនួន ១៥.០០០ រៀល (៤,៧៥ ដុល្លារសហរដ្ឋអាមេរិក) ក្នុងមួយថ្ងៃនៅតាមចម្ការតូចៗមួយចំនួន។

អ្នកស្រី បាននិយាយបន្ថែមទៀតថា នៅពេលដែលអ្នកភូមិមួយចំនួនអស់របស់របរប្រើប្រាស់ អ្នកទាំងនោះបានទៅរកអ្នកស្រីសុំជំនួយដែលរួមមានទាំងអង្ករ និងប្រាក់កំចីដែលនឹងត្រូវឲ្យសងមកអ្នកស្រីវិញនៅពេលក្រោយ។ អ្នកស្រីបាននិយាយថា ក្រុមគ្រួសារជាច្រើនបានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដើម្បីផ្គត់ផ្គង់ការចំណាយប្រចាំថ្ងៃ។

អង្គការ លីកាដូ បាននិយាយជាមួយបងប្អូនស្រី ២នាក់ដែលបានរស់នៅលើដីសម្បទានសង្គមកិច្ចអស់រយៈពេល ៤ឆ្នាំមកហើយផងដែរ។ បងប្អូនស្រីទាំងពីនាក់នោះបាននិយាយថា អង្ករដែលរក្សាទុកនៅក្នុងឃ្លាំងរបស់អ្នកទាំងពីរបានអស់អំឡុងពេលចូលឆ្នាំខ្មែរ កាលពីខែមេសា ឆ្នាំ២០១៤ ហើយចាប់តាំងពីពេលនោះមកអ្នកទាំងពីររស់នៅមួយថ្ងៃគិតមួយថ្ងៃ។ អ្នកទាំងពីរបានបន្តទៀតថា ជួនកាលវិធីតែមួយគត់ដែលអាចរកអាហារបាន គឺការខ្ចីពីអ្នកជិតខាងរបស់ខ្លួន។ អ្នកទាំងពីរមិនមានលទ្ធភាពធ្វើការបង្កបង្កើនផលឲ្យបានគ្រប់គ្រាន់លើដីស្រែនោះទេ ដោយសារតែមិនមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពលើដំណាំទាំងអស់នោះ។

កសិករម្នាក់ឈ្មោះ សារ៉ាត់ (មិនមែនជាឈ្មោះពិតរបស់គាត់ទេ) ដែលមានអាយុច្រើនជាងអ្នកដទៃទៀតបានរស់នៅលើដីសម្បទានសង្គមកិច្ចទីពោពីរដែលនៅជិតទីតាំងដីសម្បទានសង្គមកិច្ចទីពោមួយ ដែលបានរស់នៅលើដីសម្បទានសង្គមកិច្ចអស់រយៈពេល ២ឆ្នាំបានប្រាប់អង្គការ លីកាដូ ថា គាត់បានព្យាយាមដាំដើមដំលូងមីនៅលើដីស្រែចំនួន ២ហិចតាដែលបានសម្បទានមកឲ្យគាត់។ ប៉ុន្តែគាត់បាននិយាយថា គាត់មិនបានទទួលទិន្នផល

ល្អទេ ដោយសារតែដីនោះមានខ្សាច់ច្រើនពេក ហើយការខ្វះខាតទឹកសម្រាប់ស្រោចដំណាំគឺជាបញ្ហាដ៏សំខាន់។ ដោយសារតែ សារ៉ាត់មិនអាចរស់នៅលើដីស្រែដែលគាត់បានទទួល គាត់បានតាំងទីលំនៅដោយខុសច្បាប់លើផ្ទៃដីចំនួន ៣ហិចតាដែលមានទីតាំងជិតកន្លែងដែលគាត់ដាំស្រូវ ស្វាយចន្ទី និងដំលូងមី។ គាត់បាននិយាយថា គាត់អាចដាំស្រូវសម្រាប់បរិភោគរយៈពេល ៧ខែលើផ្ទៃដីចំនួន ៣ហិចតានេះ ហើយត្រូវតែធ្វើជាប្រចាំថ្ងៃ បន្ទាប់ពីអង្ករត្រូវបានគាត់ប្រើប្រាស់អស់ពីស្តុក។

សារ៉ាត់ បានអះអាងថា មានចំនួនប្រហែលជា ៦០គ្រួសារប៉ុណ្ណោះដែលរស់នៅជាក់លាក់ក្នុងឃុំទីពោ២ ហើយមានចំនួនក្រុមគ្រួសារប្រហែលជាមួយភាគបី (១/៣) តែប៉ុណ្ណោះ ដែលមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគពេញមួយឆ្នាំ។ អ្នកផ្សេងទៀតជួនកាលទៅរកអាហារតាមរយៈកម្ចីពីហាងតាមទីតាំងមួយចំនួន ឬទៅជីកដំឡូងព្រៃ។ សារ៉ាត់បានឲ្យដឹងថា អ្នកភូមិជាច្រើនដែលរស់នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចទាំងពីរកន្លែងក្នុងឃុំទីពោបានទទួលប្រាក់ចំនួលមកពីការកាប់ព្រៃ និងផលិតផលធ្យូងធ្វើអំពីអុស។

សារ៉ាត់ បានបន្ថែមទៀតថា ឃុំទីពោ២ មិនមានមណ្ឌលសុខភាពទេ ប៉ុន្តែប្រជាពលរដ្ឋអាចទៅរកថ្នាំបានពីមណ្ឌលសុខភាពដែលស្ថិតនៅក្នុងឃុំទីពោ១។ ប៉ុន្តែ សារ៉ាត់បានប្រាប់ឲ្យដឹងថា មណ្ឌលសុខភាពដែលស្ថិតនៅឃុំទីពោ១ គឺធ្វើការតែពី ១ថ្ងៃទៅ ២ថ្ងៃប៉ុណ្ណោះក្នុងមួយខែដើម្បីផ្តល់ថ្នាំដល់ក្រុមគ្រួសារទាំងនោះ។

# មូលហេតុដែលមិនជោគជ័យនៃគម្រោង LASED

ឯកសារនានាស្តីពីគម្រោង LASED របស់ធនាគារពិភពលោក មិនបានពន្យល់នូវមូលហេតុដែលនាំឲ្យគម្រោង មានការពន្យាពេល និងមានការខ្វះចន្លោះជាច្រើននោះទេ។ ការរកឃើញរបស់អង្គការលីកាដូ បានចង្អុលបង្ហាញជាចំបងទៅលើកង្វះខាតឆន្ទៈនយោបាយ។ បញ្ហានេះកាន់តែមានសភាពធ្ងន់ធ្ងរដោយសារកង្វះខាតការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ និងការគាំទ្រចំពោះការចិញ្ចឹមជីវិត។

## កង្វះឆន្ទៈនយោបាយ

នៅក្នុងឯកសាររបស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់(GTZ/GIZ) ឆ្នាំ២០១២ ស្តីពីគម្រោង LASED ដែលបានបង្ហាញថា មូលហេតុមួយក្នុងចំណោមមូលហេតុបឋមជាច្រើន នៃការមិនជោគជ័យរបស់គម្រោង LASED គឺដោយសាររាជរដ្ឋាភិបាលលោកមិនទាន់បានផ្តល់ដីគ្រប់គ្រាន់សម្រាប់សម្បទានដីសង្គមកិច្ច ដែលគាំទ្រដោយគម្រោង LASED៖

"ទោះបីជាបន្ទាប់ពីគម្រោង LASED បានដំណើរការជាមួយគម្រោងសម្បទានដីសង្គមកិច្ចទៅក្នុងឃុំចំនួន១៧ ក៏ដោយ ហើយបើទោះបីជាមានយុទ្ធនាការយ៉ាងខ្លាំងក្លា ដោយក្រសួងគ្រប់គ្រងដែនដីនគររូបនីយកម្ម និងសំណង់ នៅក្នុងឆ្នាំ២០០៧ ដែលជាលទ្ធផលនាំឲ្យមានការស្នើសុំសម្បទានដីសង្គមកិច្ចពីឃុំចំនួន ៤៤ នៅក្នុងខេត្តសាកល្បងចំនួន ៣ បន្ថែមទៀតក៏ដោយ ក៏មិនមានដីដែលត្រូវបានផ្តល់ដោយរាជរដ្ឋាភិបាល សម្រាប់សម្បទានសង្គមកិច្ចបន្ថែមនោះទៀតដែរ។ គោលបំណងជាបរិមាណសម្រាប់គ្រួសារចំនួន ១០.០០០ គ្រួសារ (គោលបំណងរបស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ GTZ/GIZ) ឬ ១០ឃុំ (គោលបំណងរបស់ធនាគារពិភពលោក) ក្នុងអំឡុងពេលឆ្នាំសាកល្បងដែលមានរយៈពេលយូរ (តាមរយៈកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ GTZ/GIZ តាំងពីឆ្នាំ២០០៥) គឺមិនត្រូវបាន សម្រេចជោគជ័យនោះទេ ដោយការផ្តល់ដីគឺបានផ្តល់ដល់ត្រឹមតែ ១.៦១៤ គ្រួសារតែប៉ុណ្ណោះទេ នៅក្នុងឃុំចំនួន ៤ [...]។ តាមវិធីសាស្ត្រនៃគម្រោង LASED ដែលអនុវត្តនៅថ្នាក់ឃុំ ឃុំជាច្រើនមិនអាចប្រជែងក្នុងការទទួលបានដីជាមួយអ្នកវិនិយោគទុនឯកជន ដែលអ្នកទាំងនោះជាអ្នកឈ្នះយ៉ាងលើសលុបក្នុងអំឡុងពេលនេះនោះទេ។"[៣៦]

**...នៅពេលដែលអាជ្ញាធរកម្ពុជាមិនអាច ឬមិនមានឆន្ទៈក្នុងការកំណត់ស្វែងរកដីគ្រប់គ្រាន់សម្រាប់សម្បទានដីសង្គមកិច្ចដល់ប្រជាពលរដ្ឋក្រីក្រនៅកម្ពុជា ដីកសិកម្មជាច្រើនត្រូវបានប្រគល់ទៅឲ្យក្រុមហ៊ុនឯកជន...**

ដូចគ្នានេះដែរ ការវាយតម្លៃអំពីបញ្ហាសិទ្ធិមនុស្សនៃកម្មវិធីសិទ្ធិដីធ្លីដែលផ្តល់ជំនួយដោយប្រទេសអាល្លឺម៉ង់(LRP)ដែលត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០១២ បានសន្និដ្ឋានថា មានភាពខ្វះខាតនូវឆន្ទៈនយោបាយរបស់ភាគីរាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់ដីឲ្យបានគ្រប់គ្រាន់សម្រាប់សម្បទានដីសង្គមកិច្ចក្រោមគម្រោង LASED។[៣៧]

ផ្ទុយគ្នាស្រឡះ នៅពេលដែលអាជ្ញាធរកម្ពុជាមិនអាច ឬមិនមានឆន្ទៈ ក្នុងការកំណត់ស្វែងរកដីគ្រប់គ្រាន់សម្រាប់សម្បទានដីសង្គមកិច្ចដល់ប្រជាពលរដ្ឋក្រីក្រនៅកម្ពុជា ដីកសិកម្មជាច្រើនត្រូវបានប្រគល់ទៅឲ្យក្រុមហ៊ុនឯកជនក្រោមរូបភាពជាសម្បទានដីសេដ្ឋកិច្ច (ELCs) និងក្រោមរូបភាពស្រដៀងគ្នាជាសម្បទានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ជារឿយៗ សម្បទានដីទាំងនេះត្រូវបានផ្តល់ដោយរំលោភលើច្បាប់ប្រទេសកម្ពុជា ពាក់ព័ន្ធនឹងទំហំដីសម្បទាន ការវាយតម្លៃពីផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមជាមុនការប្រឹក្សាយោបល់ជាមួយសហគមន៍ដែលរងផលប៉ះពាល់ បញ្ហាតម្លាភាព និងការចាត់ថ្នាក់នៃដីដែលត្រូវផ្តល់។

**ចំនួនដីដែលបែងចែកឲ្យសម្បទានដីសង្គមកិច្ចរបស់គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចប្រៀបធៀបជាមួយចំនួនដីដែលបែងចែកឲ្យសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តគោលដៅទាំងបី ពីឆ្នាំ២០០៨-២០១៥**




នៅក្នុងខេត្តដែលជាគោលដៅចំនួន ៣ នៃគម្រោង LASED ដីសម្បទានសរុបចំនួន ៥៥ កន្លែងដែលគ្របដណ្តប់លើផ្ទៃដីចំនួន ៤០០.០០០ហិកតា ត្រូវបានផ្តល់ឲ្យក្រុមហ៊ុនឯកជនសម្រាប់ការអភិវឌ្ឍកសិកម្ម ចាប់តាំងពីមានការឯកភាពពីធនាគារពិភពលោកលើគម្រោងនេះនៅក្នុងខែឧសភា ឆ្នាំ២០០៨។[៣៨] ខេត្តក្រចេះ ជាខេត្តដែលត្រូវរងផលប៉ះពាល់ពីការផ្តល់ដី ដែលអាចដាំដុះបានយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅឲ្យក្រុមហ៊ុនឯកជន។ កន្លងមក ៣៥ ភាគរយនៃផ្ទៃ

[៣៦] ឯកសាររបស់ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិ (GIZ) ទំព័រ ៦ ។
[៣៧] វិទ្យាស្ថានអាល្លឺម៉ង់សម្រាប់សិទ្ធិមនុស្ស៖ "ការវាយតម្លៃអំពីបញ្ហាសិទ្ធិមនុស្សនៃកម្មវិធីសិទ្ធិដីធ្លីកម្ពុជា-អាល្លឺម៉ង់ (LRP)" ទំព័រ ៩ ដែលមាននៅលើ http://www.institut-fuer-menschenrechte.de/uploads/tx_commerce/Study_Human_Rights_Assessment_of_the_German_Cambodian_Land_Rights_Program.pdf
[៣៨] ខេត្តក្រចេះ៖ ដីសម្បទានចំនួន ៤១ ដែលមានផ្ទៃដីសរុប ៣១៧.៦៦៨ ហិកតា។ ខេត្តកំពង់ធំ៖ ដីសម្បទានចំនួន ១០ ដែលមានផ្ទៃដីសរុបចំនួន ៤៣.១៦៧ ហិកតា។ ខេត្តកំពង់ចាម៖ ដីសម្បទានចំនួន ៤ ដែលមានផ្ទៃដីសរុបចំនួន ៣២.៨៤៤ ហិកតា។

**ស្តាំ៖** រូបភាពពីផ្កាយរណបនៃផ្នែកតូចៗនៃដីស្រែចម្ការ ក្នុងដីសម្បទានសង្គមកិច្ចក្នុងតំបន់ទីពោ១ ដោយគិតត្រឹមខែកុម្ភៈឆ្នាំ២០១៤បានបញ្ជាក់ថាមានដីតែមួយផ្នែកតូចប៉ុណ្ណោះ ដែលត្រូវបានសម្អាត និងអាចធ្វើស្រែចម្ការបាន។ រូបភាព©២០១៥ DigitalGlobe, © ២០១៥ Google, រូបភាព © ២០១៥ CNES/Astrium។

**ក្រោម៖** រូបភាពពីផ្កាយរណបបង្ហាញពីតំបន់ទីពោ១ ឃុំទីពោ ខេត្តកំពង់ធំ នៅជំហានដំបូងនៃការអភិវឌ្ឍ ដោយគិតត្រឹមខែមីនា ឆ្នាំ២០១១។ រូបភាពបង្ហាញពីដី ដែលមានគុណភាពទាបដែលមាននៅក្នុងដីកសិកម្មជាច្រើនក្នុងតំបន់ដីសម្បទានសង្គមកិច្ច។
រូបភាព © DigitalGlobe។






ដីរបស់ខេត្តនេះទាំងមូលត្រូវបានផ្តល់ឲ្យទៅក្រុមហ៊ុនឯកជន ក្នុងរូបភាពជាសម្បទានដីសេដ្ឋកិច្ច ឬដីសម្បទានដែលស្រដៀងគ្នានេះ សម្រាប់ការអភិវឌ្ឍកសិកម្ម។

ជាការកត់សម្គាល់ គម្រោង LASED មិនបានជោគជ័យក្នុងការទទួលបានដីសម្បទានសង្គមកិច្ចពីដីសម្បទានសង្គមកិច្ច ដែលនេះជាសូចនាករមួយរបស់គម្រោង LASED នេះ។[៣៩]

## ការមិនអាចសម្រេចទៅបានតាមគោលដៅនៅក្នុងការផ្តល់ការគាំទ្រលើហេដ្ឋារចនាសម្ព័ន្ធ និងការចិញ្ចឹមជីវិត

គម្រោង LASED ដែលត្រូវបានបង្កើតឡើងដោយមានការសន្មតជាមុនថា ការផ្តល់ឲ្យបានទាន់ពេលវេលានូវសេវាកម្មគាំទ្រផ្សេងៗ និងហេដ្ឋារចនាសម្ព័ន្ធនឹងត្រូវធានានូវនិរន្តរភាពសម្រាប់អ្នកទទួលបានសម្បទានដីសង្គមកិច្ច។ ដូច្នេះ គម្រោងនេះគឺ៖

"ត្រូវបានបង្កើតឡើងដើម្បីធានាថា សេវាកម្មសំខាន់ៗបំផុតជាច្រើនសម្រាប់ការតាំងលំនៅឋាន គឺត្រូវបានផ្តល់ជូន មុនពេលមានការប្រគល់ដីជូនអ្នកទទួលបានសម្បទានដីសង្គមកិច្ច។ បន្ទាប់មកគម្រោងក៏ធានានូវជំនួយសម្រាប់ការផ្តល់សេវាកម្មបន្តទៀត តាមរយៈរចនាសម្ព័ន្ធអភិវឌ្ឍជនបទវិមជ្ឈការ ដែលមានស្រាប់សម្រាប់រយៈពេលពីរឆ្នាំបន្តទៀត [...]។ បើយោងតាមបទពិសោធន៍កន្លងមកនៅក្នុងប្រទេសកម្ពុជា ប្រសិនបើផ្តល់ដោយទាន់ពេលវេលានូវដីសម្បទានសង្គមកិច្ច និងមានការគាំទ្រយ៉ាងខ្លាំងក្លារយៈពេល ៣ ឆ្នាំ គឺគួរតែគ្រប់គ្រាន់ក្នុងការធ្វើឲ្យអ្នកទទួលបានដីសម្បទានសង្គមកិច្ច ទទួលបានកម្រិតមួយនៃសន្តិសុខស្បៀង និងអាចមករស់នៅក្នុងសង្គមវិញបាន (សមាហរណកម្ម) ដែលជាការគ្រប់គ្រាន់ក្នុងការបន្តរស់នៅដោយមិនចាំបាច់មានការគាំទ្រពិសេសទៀតនោះទេ។"[៤០]

ក៏ប៉ុន្តែ របាយការណ៍នេះបានបង្ហាញថា គម្រោងនេះមិនបានទទួលជោគជ័យក្នុងការអនុវត្តជាក់ស្តែង ដើម្បីធានាថាអ្នកទទួលបានដីភាគច្រើន អាចប្រើប្រាស់ដីកសិកម្មរបស់ខ្លួនឲ្យមាននិរន្តរភាពនោះទេ។ ថ្វីត្បិតតែតាមការរាយការណ៍ថា ដំណើរការចុះបញ្ជី និងជ្រើសរើសអ្នកដែលត្រូវទទួលបានដីធ្លី សម្រាប់សម្បទានដីសង្គមកិច្ចទាំងនេះត្រូវបានបញ្ចប់នៅដើមឆ្នាំ២០១៣ ហើយក៏ដោយ។

គម្រោង LASED ក៏បានខកខាន ក្នុងការផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធឲ្យបានគ្រប់គ្រាន់ឲ្យទាន់ពេលវេលា នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចមួយចំនួនដើម្បីធានាថា គ្រួសារដែលទទួលបានដីធ្លីអាចបន្តរស់នៅលើដីទាំងនោះបន្តទៀត។ បើយោងតាមផ្ទាំងផ្សព្វផ្សាយជាច្រើនដែលបានដាក់តាមផ្លូវ សាលារៀន និងអណ្តូងទឹកនៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចថ្មីៗបំផុតចំនួន ៤ទីតាំង ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗភាគច្រើនត្រូវតែបានដាក់ឲ្យមាន តាំងពីឆ្នាំ ២០១២-២០១៣ មកម្ល៉េះ។ ប៉ុន្តែនាពេលទស្សនកិច្ចរបស់ក្រុមការងារអង្គការ លីកាដូ សាលារៀននៅក្នុងឃុំថ្មី ខេត្តក្រចេះ មិនទាន់បានបើកឲ្យដំណើរការនោះទេ។ ទីតាំងនៅក្នុងឃុំចំបក់ខេត្តក្រចេះ មានការខ្វះខាតសាលារៀន ហើយមណ្ឌលសុខភាពដែលត្រូវបានសាងសង់រួចក៏មិនទាន់ត្រូវបានបើកឲ្យដំណើរការនៅឡើយនោះដែរ។

គ្រួសារមួយចំនួន ដែលរស់នៅក្នុងទីតាំងដីសម្បទានសង្គមកិច្ចក្នុងឃុំថ្មី និងចំបក់ មិនបានបញ្ជូនកូនរបស់ខ្លួនទៅសាលារៀននោះទេ ហើយមួយចំនួនទៀតបានទុកកូនឲ្យរស់នៅម្នាក់ឯង ឬជាមួយសាច់ញាតិនៅក្នុងភូមិចាស់ ដើម្បីឲ្យកូនបានទៅសាលារៀននៅទីនោះ។ ស្ថានភាពនេះបានបន្ថែមបន្ទុកធ្ងន់ធ្ងរដល់គ្រួសារទាំងនោះដែលធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃគម្រោងបន្ថែមទៀត។

[៣៩] របាយការណ៍ស្តីពីស្ថានភាពគម្រោងរបស់ធនាគារពិភពលោក ចេញផ្សាយខែធ្នូ ឆ្នាំ២០១៤ ទំព័រ ៨។
[៤០] សូមមើលរបាយការណ៍វាយតម្លៃគម្រោង ទំព័រ១៨។



សម្ភារៈសំណង់ និងពាងទឹកដែលមិនទាន់បានប្រើប្រាស់នៅលើតំបន់ដីលំនៅឋានក្នុងតំបន់ដីសម្បទានសង្គមកិច្ច
ក្នុងឃុំថ្មី ខេត្តក្រចេះ កាលពីខែកុម្ភៈ ឆ្នាំ២០១៥



មណ្ឌលសុខភាពនៅតំបន់ដីសម្បទានសង្គមកិច្ចក្នុងឃុំជាំក្រវៀន ខេត្តត្បូងឃ្មុំ កាលពីខែមីនា ឆ្នាំ២០១៥

# សេចក្តីសន្និដ្ឋាន

គម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) មិនទទួលបានជោគជ័យក្នុងការសម្រេចឲ្យបាននូវកម្រិតជោគជ័យ ដែលទាមទារដើម្បីឲ្យក្លាយជាគម្រោងគំរូសម្រាប់ការយកទៅអនុវត្តបន្តក្នុងការកាត់បន្ថយភាពក្រីក្រ និងបង្កើនសន្តិសុខស្បៀងសម្រាប់ប្រជាពលរដ្ឋកម្ពុជាដែលក្រីក្រ និងគ្មានដីធ្លីនៅជនបទនោះទេ។ អត្រានៃការតាំងទីលំនៅក៏នៅមានកម្រិតទាបនៅឡើយ ហើយក៏ដូចគ្នាផងដែរ ចំពោះចំនួនប្រជាពលរដ្ឋទទួលបានដីធ្លីដែលអាចបង្កបង្កើនផលលើដីកសិកម្មឲ្យបានត្រឹមត្រូវ។ សុវត្ថិភាពកម្មសិទ្ធិដីធ្លីនៅតែមានលក្ខណៈមិនច្បាស់លាស់នៅឡើយ ពីព្រោះប្រជាពលរដ្ឋជាច្រើនគ្រួសារដែលទទួលបានដីធ្លីហើយ ទំនងជាមិនអាចបំពេញនូវរាល់លក្ខខណ្ឌដែលតម្រូវដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនោះទេ។ ចំណែកឯគ្រួសារដទៃទៀត ដែលបានបំពេញទៅតាមលក្ខខណ្ឌទាំងអស់នោះហើយ ក៏នៅតែមិនទាន់បានទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅឡើយដែរ។

កង្វះនៃភាពជោគជ័យរបស់គម្រោងបែងចែកដី ដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច (LASED) កើតមានឡើងដោយពុំមានអ្វីគួរឲ្យភ្ញាក់ផ្អើលនោះទេ ដោយហេតុថាធនាគារពិភពលោក និងអង្គការ GIZ មិនបានយកចិត្តទុកដាក់ទៅលើការងាររបស់រាជរដ្ឋាភិបាល ដែលមិនសូវបានផ្តល់អាទិភាពពិតប្រាកដ ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជានៅជនបទនោះទេ។ កត្តានេះក៏ជាការធានានូវភាពជោគជ័យនៃការអនុវត្តគម្រោងផងដែរ។ រាជរដ្ឋាភិបាលមានភាពយឺតយ៉ាវចំពោះដំណើរការនៃការបែងចែកដីធ្លី ហើយចំពោះករណីជាច្រើនបានផ្តល់ដីធ្លីដែរ តែមិនគ្រប់គ្រាន់សម្រាប់ការបង្កបង្កើនផលនោះទេ។ ផ្ទុយស្រឡះទៅវិញ រាជរដ្ឋាភិបាលស្របពេលនោះដែរ បានជួលដីធ្លីដែលអាចបង្កបង្កើនផលបានក្នុងទីតាំងជាមួយគ្នានោះដែរ ទៅជាសម្បទានដែលមានទ្រង់ទ្រាយធំទៅឲ្យក្រុមហ៊ុនឯកជនសម្រាប់ការអភិវឌ្ឍ។

បញ្ហាទាក់ទងនឹងការបែងចែកដីធ្លី ដោយរាជរដ្ឋាភិបាលសម្រាប់សម្បទានដីសង្គមកិច្ចកាន់តែមានភាពធ្ងន់ធ្ងរ ដោយសារ សេវាគាំទ្រមិនគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោងនេះ ពីព្រោះអ្នកទទួលបានដីសម្បទានសង្គមកិច្ចជាច្រើន មិនមានធនធានគ្រប់គ្រាន់ដើម្បីបង្កបង្កើនផលលើដីកសិកម្មដែលបានបែងចែកទៅឲ្យអ្នកទាំងនោះ នោះទេ។ ហេតុដូចនេះហើយ ពួកគាត់នៅតែបន្តរកការងារប្រចាំថ្ងៃធ្វើនៅកន្លែងផ្សេងៗដើម្បីចិញ្ចឹមជីវិតតទៅទៀត។

ធនាគារពិភពលោក និងកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GTZ/GIZ) បានអបអរសាទរចំពោះភាពជោគជ័យរបស់គម្រោងនេះ ហើយឥឡូវនេះកំពុងស្នើសុំថវិកាជាច្រើនបន្ថែមទៀត ដើម្បីគាំទ្រទីតាំងដីសម្បទានសង្គមកិច្ចដែលមានបច្ចុប្បន្ន ដោយបញ្ជាក់ថា ពួកគេឃើញថា មានកិច្ចការដែលត្រូវធ្វើបន្ថែមទៀតដើម្បីឲ្យបានទទួលនូវដំណោះស្រាយដែលមាននិរន្តរភាពសម្រាប់ប្រជាពលរដ្ឋ ដែលរងផលប៉ះពាល់។ បើទោះជាការគាំទ្របន្ថែមទៀត មានភាពចាំបាច់ដើម្បីបំពេញតាមការសន្យាក្នុងការកាត់បន្ថយភាពក្រីក្រ និងបង្កើនសន្តិសុខស្បៀងសម្រាប់គ្រួសារជាច្រើន ដែលទទួលការគាំទ្រពីគម្រោងនេះក៏ដោយ ក៏ធនាគារពិភពលោក និងភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GTZ/GIZ) ដំបូងត្រូវទទួលស្គាល់ថា គម្រោងនេះមិនទាន់អាចជាគម្រោងគំរូមួយបានទេសម្រាប់ឲ្យគេយកទៅអនុវត្តតាម ហើយក៏មិនទាន់ជាគម្រោងដ៏ជោគជ័យដែរ ទោះជាវាស់វែងតាមបទដ្ឋានណាក៏ដោយ។ ធនាគារពិភពលោក និងភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់(GTZ/GIZ) មានកាតព្វកិច្ចក្នុងការឧបត្ថម្ភគាំទ្រ ចំពោះប្រជាពលរដ្ឋកម្ពុជាក្រីក្រនៅទីជនបទដែលមានការគាំទ្រពីគម្រោង LASED នេះ ប៉ុន្តែការឧបត្ថម្ភគាំទ្រទាំងនោះត្រូវតែអនុវត្តទៅប្រកបដោយការទទួលខុសត្រូវជាមួយនឹងការខិតខំប្រឹងប្រែងពិតប្រាកដ ដើម្បីធានាឲ្យបាននូវភាពប្រសើរឡើងនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលទទួលបានដីធ្លីនេះ។

www.licadho-cambodia.org